Formation, Dialogue, Cooperation

# អ្នកនាំសារ

The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៤ ថ្ងៃទី០១-៣០ ខែមិថុនា ឆ្នាំ២០១១ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៤៦

## មាតិកា



ហ្វេសបុក (Face book) ពេញនិយម ទំព័រ ៥



ជេអេសស៊ី សម្ពោធមត្តេយ្យ ទំព័រ ៧



កិច្ចប្រជុំលើកទី១របស់ក្រុមបុព្វជិត... ទំព័រ ១៤

# ព្រះសហគមន៍ : ការអប់រំគឺជាមូលដ្ឋានគ្រឹះរបស់ប្រទេស និងជាយុទ្ធនាការកាត់បន្ថយភាពក្រីក្រ



ការអប់រំគឺជាវិស័យដ៏សំខាន់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សដើម្បីអភិវឌ្ឍជាតិមួយ។ ហើយដើម្បីបង្កើតឱ្យមានធនធានមនុស្សដែលប្រកបទៅដោយគុណភាពនោះ ការអប់រំនេះត្រូវចាប់ផ្ដើមដោយឆ្លងកាត់តាមគ្រប់កម្រិតចាប់តាំងពីមត្តេយ្យសាលា រហូតដល់ឧត្ដមសិក្សា និងក្រោយឧត្ដមសិក្សា។ ក្នុងនោះដែរ ព្រះសហគមន៍កាតូលិកនៅកម្ពុជាក៏បានចូលរួមអភិវឌ្ឍវិស័យអប់រំនេះលើគ្រប់កម្រិតដែរ។ ទំព័រទី១០_១១

កម្មវិធីវិទ្យុ

## អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប : FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ



ព្រះសង្ឃចំនួន ២.៦០០អង្គ ក្នុងទិវាគម្រប់ខួប២.៦០០ឆ្នាំ ដែលព្រះពុទ្ធបានចូលបរិនិព្វាន ថ្ងៃបុណ្យពិសាខបូជានៅមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ កាលថ្ងៃទី១៧ ខែឧសភា។



ថ្ងៃទី០៥ មិថុនា គឺជាថ្ងៃឱសានវាទនៃយុទ្ធនាការបង្ក្រាបបទល្មើស និងអនាធិបតេយ្យនេសាទ ក្នុងខេត្តទាំង៨ ជុំវិញបឹងទន្លេសាប។



លោកសម្បត្តិធ្វើការប្រមូលអ្វីៗដែលអាចលក់បាន ឬស្វែងរកឯកសារ ដើម្បីសិក្សាដោយខ្លួនឯងពីកាសែតចាស់ៗ ដែលលោកប្រមូលបាន



ព្រះរាជពិធីច្រត់ព្រះនង្គ័លប្រារព្ធធ្វើនៅវាលព្រះមេរុ ខាងជើងព្រះបរមរាជវាំងរាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះបាទនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃកម្ពុជា។



តម្លៃប្រេងសាំងកើនឡើង ប្រជាពលរដ្ឋទាំងអ្នកប្រើប្រាស់ និងអ្នកលក់មានការត្អូញត្អែរដូចគ្នា ពីព្រោះជីវភាពពួកគាត់មានការលំបាក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី
សម្តេចព្រះមហាសង្ឃរាជ នៃ ព្រះរាជាណាចក្រកម្ពុជា

ចន្ទ្ទឧណ្ណាលោម
លេខៈ ៣៧៨ ម.ស.រ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០១១

**សូមចម្រើនពរ**
**លោកអភិបាល អូលីវីយេ ឌ្វីតអឺស្តែរ**
**អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ**

**លោកអភិបាលជាទីស្រឡាញ់រាប់ដ៏ថ្លាថ្លៃ**

ខ្ញុំព្រះករុណា អាត្មាភាពបានទទួលរួចហើយលិខិតរបស់លោកអភិបាល ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១ ដែលបានសម្តែងនូវអំណរសប្បាយ គារវកិច្ច និងសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ជូនខ្ញុំព្រះករុណាអាត្មាភាពព្រមទាំងប្រគេន និងជូនព្រះថេរា នុត្ថេរៈ គ្រប់ព្រះអង្គ និងបងប្អូនពុទ្ធបរិស័ទក្នុងឱកាសបុណ្យវិសាខបូជា ពេញបូណ៌មី នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១១កន្លងមកនេះ។

ក្នុងនាមសហគមន៍ព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្ញុំព្រះករុណា អាត្មាភាពផ្ទាល់សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនលោកអភិបាល ព្រមទាំងគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកទាំងអស់ ដែលបានគាំទ្រ និងផ្តល់នូវកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនិងសហគមន៍ព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមសម្តែងនូវសេចក្តីអរគុណ និងសូមប្រគេនពរថ្វាយ **សម្តេចប៉ាប បេណេឌីក ទី១៦** និង **ក្រុមប្រឹក្សាអភិបាលព្រះសហគមន៍** នៃទីក្រុងរ៉ូម ដែលបានថ្វាយព្រះពរនាឱកាសនៃការប្រារព្ធពិធីបុណ្យវិសាខបូជាពេញបូណ៌មីផងដែរ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាអាត្មាភាព សូមប្រគេនពរជូនលោកអភិបាល បូជាចារ្យ បព្វជិត បព្វជា និងគ្រីស្តបរិស័ទកាតូលិកទូទាំងព្រះរាជាណាចក្រកម្ពុជា សូមបានប្រកបដោយសេចក្តីសុខ និងសេចក្តីចម្រើន និងសូមឱ្យចំណងទាក់ទងរវាងសហគមន៍ព្រះពុទ្ធសាសនា និងព្រះសហគមន៍កាតូលិកឋិតថេរជាអមតៈតរៀងទៅ។

**ដោយសេចក្តីស្រឡាញ់រាប់អានក្នុងព្រះធម៌**

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស**
**សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា**

# ក្រុមគ្រូពេទ្យ និងនិស្សិតសិង្ហបុរី មកថែទាំសុខភាព

ក្រុមគ្រូពេទ្យ និងនិស្សិតពេទ្យសិង្ហបុរីប្រមាណ ៤០នាក់ ផ្តល់ការប្រឹក្សាយោបល់ និងពិនិត្យសុខ-ភាព ដល់ប្រជាពលរដ្ឋក្រីក្រប្រមាណ ៤០០ ទៅ ៥០០នាក់ កាលពីថ្ងៃទី២៣ ដល់ថ្ងៃទី៣១ ឧសភា នៅមណ្ឌលកសិកម្មគ្រាប់ នាខេត្តពោធិ៍សាត់ នៅភូមិភាគកាតូលិកបាត់ដំបង។

លោកបូជាចារ្យ ហ៊ៃណាន់ ពីនីយ៉ា អ្នកទទួលខុសត្រូវមណ្ឌលកសិកម្មគ្រាប់ និងជារៀបចំកម្មវិធីសុខភាព ព្រះសហគមន៍បាននិយាយថា កម្មវិធីនេះធ្វើឡើងរៀងរាល់ ២ឆ្នាំម្តង។ ហើយឆ្នាំនេះ ធ្វើនៅតំបន់ជាច្រើន រួមមាន មណ្ឌលកសិកម្មគ្រាប់ ព្រះសហគមន៍កំពង់ហ្លួង រលួស ជំនាល តាកែវ និងជាមុន្នីជាដើម។ លោកបូជាចារ្យ បានបញ្ជាក់ថា ក្រុមគ្រូពេទ្យ និងនិស្សិតសិង្ហបុរី មានកម្មវិធីសំខាន់៧ បី រួមមានទីមួយការអប់រំសុខភាពសិស្សានុសិស្សនៅតាមសាលារដ្ឋនានា ការចុះអប់រំប្រជាជនតាមភូមិពីសុខភាព ទីពីរការជីកអណ្តូងទឹក និងការ ពន្យល់អំពីបរិស្ថានដល់ ប្រជាពលរដ្ឋ ហើយទីបីគឺការផ្តល់ប្រឹក្សាយោបល់ និងពិនិត្យសុខភាព។

លោកបូជាចារ្យបន្តថា កម្មវិធីនេះជួយអ្នកក្រី




ក្រឱ្យទទួលបានការពិនិត្យ និងព្យាបាលសុខភាពឥតគិតថ្លៃ និងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការថែរក្សាសុខភាពរបស់ប្រជាជនតាមភូមិ។

**ថុង យ៉េត**

# សេដ្ឋកិច្ច

## អតិផរណាកើន ពេលសាំងឡើងជាង៥០០០រៀល

**ខាន់ ភីរម្យ**

ទំនិញប្រើប្រាស់ ជាពិសេស គឺតម្លៃម្ហូបអាហារ បានចាប់ផ្ដើមឡើងថ្លៃក្រោយពេលដែលតម្លៃសាំង បានហក់ឡើងរហូតដល់ជាង ៥០០០រៀលសម្រាប់ មួយលីត្រ។

បងស្រីនុប ធី ដែលជាកម្មករកាត់ដេរមួយរូប បានអះអាងថា: "ឥឡូវនេះ ម្ហូប ៥០០០រៀល ខ្ញុំ លែងទិញបានហើយ សូម្បីតែកូនត្រីមួយគីឡូក្រោម យ៉ាងហោចណាស់ ក៏៧៥០០រៀលដែរ"។

លោកឃី សាគុណ អ្នករត់ម៉ូតូឌុបមួយរូប បាន អះអាងដែរថា លោកពិបាករកម្ហូបណាស់នៅពេល ឥឡូវនេះ។ សាំងឡើងថ្លៃ! ហើយម្ហូបអាហារ ក៏ ឡើងថ្លៃ។ ចំណែកអ្នកជិះវិញ ឱ្យតែតម្លៃដដែល។ លោកបានបញ្ជាក់ឱ្យដឹងទៀតដែរថា : "ទោះបីជា សាំងមានតម្លៃឡើងដល់មួយលីត្រ ៥១៥០រៀល ក៏អ្នកជិះឱ្យតែដដែល។ បើរាល់ដង គេធ្លាប់ជិះ គេ ឱ្យ ៣០០០រៀល គេនៅតែឱ្យយើង ៣០០០រៀល ដដែល ខណៈតម្លៃអាហារ ដូចជាបបរសមួយចាន ពីមុនថ្លៃ ១៥០០រៀល ឥឡូវ វាឡើងដល់ ២០០០ រៀល ទើបទិញបានហូប"។

យោងតាមព័ត៌មានពីក្រសួងពាណិជ្ជកម្មបានឱ្យ ដឹងថា តម្លៃស្បៀងអាហារនៅតាមបណ្ដាទីផ្សារនា



□hoto : J. □hilong

នាក្នុងរាជធានីភ្នំពេញមានការឡើងថ្លៃ ជាពិសេស គឺ តម្លៃសាច់ជ្រូក និងត្រីឆ្អើរ។ ប្រភពដដែលនោះ បានឱ្យដឹងទៀតដែរថា អតិផរណា នាពេលសព្វថ្ងៃ នេះបានកើនឡើងរហូតដល់ទៅដល់ ៤១%។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ តម្លៃអង្ករហាក់ដូចជា នៅស្ថិរភាពជាមួយ និងការកើនឡើងត្រឹមតែ ២% តែប៉ុណ្ណោះ។

ជុំវិញបញ្ហានេះ ឯកឧត្តមគាត ឈន់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអះអាងកាលពី ពេលថ្មីៗនេះ នៅទីស្ដីការក្រសួងថា ការកើនឡើង នូវអតិផរណាគឺជាបញ្ហាមួយដែលអាចនឹងប៉ះពាល់ ដល់អ្នកក្រីក្រ។ ប៉ុន្តែនេះគឺជាឱកាសមួយសម្រាប់ កសិករផងដែរ។ ឯកឧត្តមរដ្ឋមន្ត្រី បានបន្តទៀត ថាអតិផរណានៅកម្ពុជា ពិតជាមានមែន។ ប៉ុន្តែបើ ប្រៀបធៀបទៅនឹងបណ្ដាលប្រទេសដទៃ គឺកម្ពុជា នៅមានស្ថានភាពល្អប្រសើរជាង។

### អត្រាអតិផរណានៅកម្ពុជា

បើយោងតាមវិទ្យាស្ថានស្ថិតិ បានឱ្យដឹងថា នៅដើមត្រីមាសទីមួយនៃឆ្នាំ តម្លៃអតិផរណា បានកើនឡើងប្រមាណជា ៣,៦% បើប្រៀប ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំកន្លងទៅ។

ទន្ទឹមនឹងនេះដែរ ស្ថាប័នហិរញ្ញវត្ថុធំៗបាន ព្យាករណ៍ថា នៅឆ្នាំនេះ អតិផរណានៅ ប្រទេសកម្ពុជា មានចាប់ពី៥% ទៅដល់៦,៥%។ តួយ៉ាងធនាគារពិភពលោក បានធ្វើការព្យាករ ឱ្យដឹងថា អតិផរណានៅកម្ពុជា នៅក្នុងឆ្នាំ ២០១១នេះ គឺមាន ៥%។ ចំណែកធនាគារ អភិវឌ្ឍន៍អាស៊ី បានអះអាងថាមាន ៥,៥% នាខណៈដែលមូលនិធិរូបិយប័ណ្ណពិភពលោក ឬ IMF បានអះអាងថា អតិផរណានឹងមាន អត្រាកើនឡើងប្រមាណ ៦,៥%។

តម្លៃប្រេងឥន្ធនៈ នៅក្នុងប្រទេសកម្ពុជា ត្រូវ បានគេអះអាងថា បានកើនឡើងប្រមាណជា ៦% ខណៈដែលលុយដុល្លារ បានធ្លាក់ចុះប្រមាណជា២% បើប្រៀបធៀបនឹងលុយរៀល ទន្ទឹមពេលដែលការ ទូទាត់ផ្សេងៗនៅក្នុងជីវភាពរស់នៅប្រើប្រាស់ជា លុយរៀល។ ផ្ទុយមកវិញប្រាក់បៀវត្សរបស់បុគ្គ- លិកក្រុមហ៊ុន ឬអង្គការភាគច្រើន គឺគេគិតសុទ្ធតែ ដុល្លារ លើកលែងតែមន្ត្រីរាជការ។

# សុខភាព

## នៅរដូវវស្សា ប្រជាពលរដ្ឋគួរយកចិត្តទុកដាក់លើជំងឺគ្រុនឈាមកើតលើកូន

**ជាត សំភី**

នៅរដូវវស្សា ជំងឺដែលគេសង្កេតឃើញកើតជា ញឹកញាប់ គឺជំងឺគ្រុនឈាម ដែលជាជំងឺមួយដ៏កាច សាហាវ ហើយអាចធ្វើឱ្យកូនចៅប្រជាពលរដ្ឋ បាត់ បង់ជីវិតបាន ប្រសិនបើមិនបានទទួលការព្យាបាល ទាន់ពេលវេលាទេនោះ។

យោងតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ហែម សុខហន នៃមន្ទីរពេទ្យកុមារជាតិបានឱ្យដឹង ថា ជំងឺគ្រុនឈាមបង្កឡើងដោយមូលខ្លា។ ហើយ មូលខ្លានេះពងកូននៅទឹកដក់ថ្លា។

លោកវេជ្ជបណ្ឌិត ក៏មានប្រសាសន៍បន្តថា មូស ខ្លានេះ វាច្រើនខាំកុមារនៅពេលថ្ងៃ និងនៅកន្លែង ងងឹត។ នៅពេលមូសខ្លាខាំហើយ ប្រហែលជាមួយ



□hoto : J. □hilong

អាទិត្យ គេឃើញកុមារមានក្ដៅខ្លួនខ្លាំង។ ហើយ ការក្ដៅខ្លួនរបស់កុមារ មិនឆ្លើយតបនឹងថ្នាំ បញ្ចុះ កម្ដៅ។ ក្រៅពីនេះ គេសង្កេតឃើញនូវរោគសញ្ញា មួយចំនួនទៀតដូចជាឈឺឆ្អឹងឆ្អែង ហូបអាហារមិន បាន ឈឺពោះ ហើយជួនកាលមានរាគរូស...។ គេក៏ ឃើញកុមារមានឆ្អូតក្រហមនៅដើមដៃ និងនៅលើ ទ្រូង និងចេញឈាមនៅតាមអញ្ចាញធ្មេញ ព្រម ទាំងមានរោគសញ្ញាជាច្រើនទៀត។

លោកវេជ្ជបណ្ឌិតហែម សុខហន គូសបញ្ជាក់ ថា: "គ្រាន់តែឃើញសញ្ញាឡើងកម្ដៅមិនចុះ យើង ត្រូវយកកុមារ មកកាន់មន្ទីរពេទ្យ ជាបន្ទាន់ ដើម្បី ស្វែងរកវិនិច្ឆ័យឱ្យបានត្រឹមត្រូវ។ការយឺតយ៉ាវមក កាន់មន្ទីរពេទ្យអាចឱ្យកុមារស្លាប់ ព្រោះបើសភាព ជំងឺធ្ងន់ធ្ងរហើយគ្រូពេទ្យលំបាកនឹងជួយណាស់"។

លោកបន្តថា ដើម្បីការពារជំងឺគ្រុនឈាមយើង ត្រូវការពារខ្លួនកុំឱ្យមូសខាំ ដូចជា គេងក្នុងមុង ឬ ពាក់ខោអាវដៃជើងវែង។ យើងត្រូវរៀបចំបរិស្ថាន ក្នុងផ្ទះនិងក្រៅផ្ទះឱ្យបានស្អាត ព្រមទាំងកប់ចោល អំបែងដប អំបែងឆ្នាំង ឬកង់ឡាន... និយាយរួមអ្វី ដែលអាចដក់ទឹកបាន-ល-។



□hoto :J. □hilong

# យុវវ័យភាគច្រើនពេញនិយមប្រើហ្វេសបុក (Facebook) ដើម្បីកំសាន្ត

**ខាន់ ភីរម្យ**

តើហ្វេសបុកជាអ្វីទៅ ? តើគេប្រើវាដើម្បីអ្វី ? តើយុវជនសព្វថ្ងៃនេះស្គាល់ហ្វេសបុកនេះទេ? នេះគឺជាសំនួរដែលយុវវ័យមួយចំនួន គាត់នឹងឆ្លើយដូចខាងក្រោមនេះ :

ហ្វេសបុកជាគេហទំព័រមួយលើបណ្តាញអ៊ីនធឺណិត ។ ដោយសារប្រជាប្រិយភាព និងតួនាទីរបស់ហ្វេសបុក ដែលកំពុងទទួលបានការពេញនិយម នាពេលនេះ សូម្បីតែស្នាដៃចម្រៀង ក៏មានតែងនិពន្ធដែលពាក់ព័ន្ធហ្វេសបុកនេះ ជាច្រើនបទផងដែរ ។

លោករិទ្ធី យុវជនអ្នកមើលការខុសត្រូវ នៅក្នុងផ្ទះសំណាក់មួយបានប្រាប់ឱ្យដឹងថាតាមការសង្កេតរបស់ខ្ញុំមកដល់ពេលនេះមានបទចម្រៀងប្រមាណជាជិត១០បទហើយ ដែលគេនិពន្ធទាក់ទងទៅនឹងហ្វេសបុកនេះ ។ លោកបញ្ជាក់ថា : "អ្នកចម្រៀងច្រៀងអំពីហ្វេសបុកមានទាំងស្រី និងទាំងប្រុស" ។ បទចម្រៀងដែលរិទ្ធីបានឱ្យដឹងនោះ មានដូចជាបទស្រក់ទឹកភ្នែកពេលលេងហ្វេសបុក ហ្វេសបុកផ្តាច់ស្នេហ៍ ហ្វេសបុករំខានស្នេហ៍ ផ្ញើទឹកភ្នែកតាមហ្វេសបុក និងហ្វេសបុកធ្វើឱ្យឈឺចាប់ជាដើម ។

ឆ្លងទៅតាមអត្ថបទចម្រៀងទាំងអស់នេះ គេអាចសម្គាល់ឃើញថា តួនាទីរបស់ហ្វេសបុក ភាគច្រើនគឺត្រឹមតែទំនាក់ទំនងតាមរបៀបយុវវ័យ និងផលប៉ះពាល់នៃទំនាក់ទំនងរបស់យុវវ័យនៅក្នុងការប្រើហ្វេសបុកនេះតែប៉ុណ្ណោះ ។ ប៉ុន្តែតាមពិតទៅ តួនាទីរបស់ហ្វេសបុកមានច្រើនជាងនេះ ។

យុវជនកែវ ខេមរិន យុវនិស្សិតអាយុ ២២ឆ្នាំមួយរូប បានឱ្យដឹងថា ហ្វេសបុកគឺជាវិបសាយមួយដែលមានមុខងារច្រើន ដូចជា ចែករំលែកព័ត៌មានទំនាក់ទំនងអប់រំ ស្វែងរកមិត្ត បង្ហាញពីស្នាដៃ និងអាចផ្សព្វផ្សាយពាណិជ្ជកម្មក៏បានដែរ ។ លោកបានបញ្ជាក់ថា: "នេះគឺមិនមែនជាវិបសាយសម្រាប់តែស្នេហាទេ ។ វាមានមុខងារច្រើនណាស់" ។ ខេមរិនបានឱ្យដឹងថាសព្វថ្ងៃនេះវិបសាយដែលមានរបៀបជាហ្វេសបុកនេះ មានច្រើនណាស់ដែរ ដូច ថាហ្គេតហាយហ្វាយជាដើម ។ ប៉ុន្តែក្នុងចំណោម វិបសាយទាំងនោះ ហ្វេសបុក ឥឡូវនេះ ដូចជា ពេញនិយមជាងគេដោយសារតែ វាមានមុខងារច្រើនមុខ នៅក្នុងនោះដូចជាការជជែកគ្នា តាមរយៈការសរសេរ (**Chat**) បញ្ជូនសារស្តាប់ចម្រៀងមើលវីដេអូ និងបង្ហោះរូបភាពជាដើម ។ ខេមរិន បញ្ជាក់ទៀតថា : "ខ្ញុំចូលចិត្តបង្ហោះរូប និងអានព័ត៌មានដែលគេចែកគ្នាតាមរយៈហ្វេសបុក" ។

យុវនារី ស ស្រីដេត យុវសិស្សវិទ្យាល័យឥន្ទ្រទេវី អះអាងថា ហ្វេសបុកគឺជាវិបសាយមួយដែលខ្ញុំតែងប្រើប្រាស់ដើម្បីធ្វើការទំនាក់ទំនងមិត្តភក្តិ ។ ស្រីដេតបានបញ្ជាក់ថា : "មកដល់ពេលនេះ ខ្ញុំមានមិត្តភក្តិតាមហ្វេសបុកនេះចំនួន ៣០នាក់" ។

លោកព្រាប កុល ឯកអគ្គរាជទូតសន្តិភាព នៅសហព័ន្ធសន្តិភាពពិភពលោក មានប្រសាសន៍ថា លោកតែងតែប្រើប្រាស់ហ្វេសបុក ជាប្រចាំ ហើយមូលហេតុដែលលោកប្រើប្រាស់នោះ គឺលោកមានគោលដៅអប់រំយុវជនតាមរយៈសារ និងការចែករំលែក បទពិសោធន៍ផ្សេងៗ ដែលលោកមាន ។

ក្រៅពីតួនាទីខាងលើនេះ មានមនុស្សមួយក្រុមផ្សេងទៀត ដែលកំពុងតែប្រើប្រាស់ហ្វេសបុកនេះបានចងក្រងគ្នា រៀបចំជាក្រុមមួយ ហើយធ្វើការរៃអង្គាសប្រាក់ដើម្បីកិច្ចការមនុស្សធម៌ផងដែរ ។

តាមរយៈការប្រើប្រាស់ហ្វេសបុកនេះ ក្រុមគេបានប្រកាសប្រមូលផ្តុំគ្នា និងរៀបចំឡើងជាកម្មវិធីមនុស្សធម៌មួយ នៅផ្សារទំនើបស៊ីធីម៉ល រាជធានីភ្នំពេញ ដើម្បីជួយដល់កុមារក្រីក្រ នៅថ្ងៃទី១ ខែមិថុនា គឺនៅចំថ្ងៃទិវាកុមារអន្តរជាតិ ។

លោកស៊ីវ សុខឿន ស្ថាបនិកនៅក្រុមនេះ បានអះអាងប្រាប់អ្នកសារព័ត៌មាន ថា មូលហេតុដែលឈានដល់ការបង្កើតនូវកម្មវិធីនេះ គឺដើម្បីជុំវិញឱ្យយុវជនខ្មែរចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ឱ្យចំគោលដៅ និងមានប្រយោជន៍សម្រាប់សង្គម ។

# ការផ្សាំកូនផ្កា និងកូនឈើគឺជារបរអាចជួយចិញ្ចឹមជីវភាព

**ជាត សំភី**



នៅតាមបណ្ដោយផ្លូវជាតិលេខពីរ មានចម្ងាយប្រហែល ១៥គីឡូម៉ែត្រ ខាងត្បូង រាជធានីភ្នំពេញ គេសង្កេតឃើញគេហដ្ឋានជាច្រើន មានលំអរទៅដោយកូនផ្កា និងកូនឈើជាច្រើន។ តាមពិតកូនផ្កា និងកូនឈើទាំងនោះ គេមិនមែនដាំសម្រាប់លំអទេ គឺគេកំពុងផ្សាំពួកវាដើម្បីលក់រាយ និងលក់ដុំ។

អ្នកស្រីសាន់ ម៉ាលីន អ្នកភូមិតាក្ដុល ឃុំតាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល មានប្រសាសន៍ថា អ្នកស្រីផ្សាំតែដើមផ្កានេះ ពីព្រោះវាងាយស្រួលលក់។ អតិថិជនរបស់អ្នកស្រីមកពីបណ្ដាខេត្តនានា ដូចជាខេត្តកំពង់ចាម ឬបាត់ដំបង...។ អ្នកខ្លះមកទិញម្ដង ពី២០០ ទៅ៣០០កន្ទោង ដើម្បីយកទៅលក់បន្ត។ ហើយអ្នកខ្លះទៀតគេទិញទៅលំអគេហដ្ឋានរបស់ពួកគេ ដោយមួយកន្ទោងផ្កាមានតម្លៃចាប់ពី ២០០ រហូតដល់ ១០០០រៀល។

នៅក្នុងសួនរបស់អ្នកស្រី គេសង្កេតឃើញផ្កាជាច្រើនប្រភេទដូចជាកន្ទុយមាន់ស្លឹកល្អិត ជើងបង្កងសៀងម៉ៃ ស្លឹក ល្មុត និងផ្កាជាច្រើនប្រភេទទៀត។ អ្នកស្រីសាន់ ម៉ាលីន រៀបរាប់ថា ដើម្បីផ្សាំផ្កាទាំងនេះ គឺមុនដំបូងយើងត្រូវកាត់ត្រួយផ្កា។ រួចយើងលាបថ្នាំជំនួយឫស ហើយដាក់ទៅក្នុងកន្ទោងដែលមានដាក់ដី ដែលយើងបានរៀបចំ រួចគ្របវាដោយចំបើង។ ដីក្នុងកន្ទោង ដែលមានដីទន្លេ ជីអំពុក និងផេះអង្កាម។ រយៈពេល១ខែ ផ្កាដុះ យើងអាចបើកបាន លុះមួយអាទិត្យក្រោយ ទើបយើងអាចយកដាក់លក់បាន។ អ្នកស្រីសាន់ ម៉ាលីន បានគូសបញ្ជាក់ឱ្យដឹងថា: "ខ្ញុំមានអារម្មណ៍សប្បាយចិត្ត ពីព្រោះទោះបីជាមុខរបរនេះ វាមិនបានជួយយើងឱ្យមានជីវភាពធូរធាខ្លាំងក្ដី ក៏ជួយឱ្យយើងអាចជំនួសប្រាក់ខែយើងខ្លះៗ និងជួយកូនៗ ឱ្យបានរៀនសូត្រដូចគេ ដូចឯងដែរ"។

នៅមិនឆ្ងាយនោះប៉ុន្មាន គឺគេហដ្ឋានរបស់អ្នកស្រីផុន ស៊ីនួន នៅភូមិបត់តាជី ឃុំព្រែកហូរ ស្រុកតាខ្មៅ ខេត្តកណ្ដាល។ អ្នកស្រីក៏ផ្សាំកូនស្វាយកែវល្មៀត និងស្វាយកែវចិន ២៨ឆ្នាំមកហើយ។ អ្នកស្រីផុន ស៊ីនួន មានប្រសាសន៍ឱ្យដឹងថា ដើម្បីផ្សាំកូនស្វាយ មុនដំបូងគេកាប់យកគ្រាប់។ រួចធ្វើដីឱ្យស្អាតម៉ត់ដែលជាប្រភេទដីទន្លេ។ គេលើកជារងរួចចុចគ្រាប់ ហើយគ្របចំបើង។ ពីប្រាំថ្ងៃទៅមួយអាទិត្យ គ្រាប់ចាប់ផ្ដើមដុះ។ ដុះបានមួយខែ ឬពីរខែ ទើបយើងដាក់លក់នៅ ពេលកម្ពស់វាបានត្រឹមចង្កេះ។ អតិថិជនមកពីបណ្ដាលខេត្តផ្សេងៗ។ គេទិញយកទៅដាំនៅចំការ។ អ្នកស្រីមានប្រសាសន៍ថា: "នេះជាមុខរបរនឿយហត់មួយ។ ប៉ុន្តែវាអាចបានលុយល្មមចិញ្ចឹមជីវភាពដែរ"។

---

**បរិស្ថាន**

## UNDP : ដីនៅកម្ពុជាប្រមាណជា ៧០% ជាដីដែលមានជីជាតិតិច និងមធ្យម

ដីនៅក្នុងប្រទេសកម្ពុជា ដោយរួមទាំងផ្ទៃដីដាំដុះដំណាំស្រូវ ប្រមាណជា ៧០% ត្រូវបានមន្ត្រីនៃអង្គការកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ហៅកាត់ថា យូអិនឌីភី (UNDP) អះអាងថា ដីអស់ទាំងនោះគឺជាដីមានជីជាតិតិច ឬមធ្យម។

លោកស្រីអេលីណា តេឆេនកូ តំណាងយូអិនឌីភីប្រចាំនៅកម្ពុជា បានមានប្រសាសន៍នៅសិក្ខាសាលាមួយស្ដីអំពីការប្រយុទ្ធប្រឆាំងនឹងឱនភាពដីនៅកម្ពុជាថា ប្រមាណជា ៧០%នៃដីនៅក្នុងប្រទេស គឺជាដីដែលមានជីជាតិតិច និងមធ្យម ហើយវាកំពុងប្រឈមមុខនឹងភាពរិចរិលថែមទៀត ដោយសារការធ្លាក់ចុះនូវគម្របព្រៃឈើ។ លោកស្រី បានឱ្យដឹងថា នៅក្នុងខេត្តមួយចំនួនដូចជាសៀមរាប កំពង់ធំ កំពង់ស្ពឺ បាត់ដំបង និងក្រចេះ គេបានរកឃើញថា ប្រព័ន្ធធម្មជាតិ ដូចជាព្រៃឈើ និងអនុផលមានការធ្លាក់ចុះ។

លោកអ៊ុក សុខុន រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានអះអាងថា ការសឹករិចរិលគុណភាពដីគឺមាន។ ប៉ុន្តែមិនច្រើនទេ។ ហើយការសឹករិចរិលនៃគុណភាពដីគឺបណ្ដាលមកពីគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត និងខ្យល់ព្យុះជាដើម។

លោកស្រីអេលីណាតេឆេនកូ បានឱ្យដឹងថា ការធ្លាក់ចុះនូវគុណភាពដី អាចប៉ះពាល់ទៅដល់សង្គមសេដ្ឋកិច្ចកម្ពុជាដោយសារតែវិស័យកសិកម្ម គឺជាមូលដ្ឋានមួយនៃកំណើនសេដ្ឋកិច្ច។



**ខាន់ ភីរម្យ**

# អង្គការព្រះសហគមន៍កាតូលិក

# ជេអេសស៊ីសម្ពោធមត្តេយ្យសាលាដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ

**ជាត សំភី**

ពិធីសម្ពោធអគារសិក្សាមត្តេយ្យសាលារស្មីកុមារនៅឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល បានធ្វើឡើង ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត រស់ វណ្ណា ទីប្រឹក្សាសម្តេចជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២១ ឧសភា ឆ្នាំ២០១១កន្លងទៅនេះ។ កម្មវិធីនេះមានការចូលរួមពីឯកឧត្តម អ៊ូ សំអួន អភិបាលរងខេត្តកណ្តាល លោកឪពុកប្រ៉ែក ប្រធានប្រចាំប្រទេសនៃអង្គការជេអេសស៊ី លោកអ៊ូ មិញហួរ តំណាងសហគ្រាសកាត់ដេររោងចក្រតៃយៀន និងខាំវែល មន្ត្រីមានសមត្ថកិច្ច គ្រប់ជាន់ថ្នាក់ ក្រុមប្រឹក្សាឃុំ លោកគ្រូអ្នកគ្រូ ប្រជាពលរដ្ឋ យុវជនកាយរិទ្ធ និងភ្ញៀវកិត្តិយសដទៃទៀតយ៉ាងច្រើនកុះករ។

នៅក្នុងឱកាសនោះ លោកបូជាចារ្យប្រ៉ែកមានប្រសាសន៍ថា : "សាលាមត្តេយ្យគឺជាថ្នាលបណ្តុះបណ្តាលដ៏សំខាន់ជួយឱ្យកុមារាកុមារីមានការរីកចម្រើនទាំងខាងកម្លាំងកាយ និងកម្លាំងប្រាជ្ញា"។ លោកបូជាចារ្យគូសបញ្ជាក់ថា : "កុមារដែលឆ្លងកាត់សាលាមត្តេយ្យតែងតែមានទំនុកចិត្តលើខ្លួនឯងច្រើនជាងកុមារដែលមិនឆ្លងកាត់ ដែលជាកត្តាមួយដ៏សំខាន់ ដើម្បីឱ្យពួកគេទទួលជោគជ័យ ក្នុងការសិក្សា និងក្នុងជីវិតខ្លួននាពេលអនាគត "។

ឯកឧត្តមបណ្ឌិតរស់ វណ្ណា ក៏ឯកភាពទាំងស្រុងនឹងប្រសាសន៍របស់ លោកបូជាចារ្យប្រ៉ែក ដោយឯកឧត្តមបន្ថែមថា អង្គការជេអេសស៊ី មិនត្រឹមតែសាងសង់អគារនេះទេ តែបានកសាងនូវសមិទ្ធផលជាច្រើន។ អង្គការជេអេសស៊ីចូលរួម ចំណែកយ៉ាងសកម្មភាពក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស។ ឯកឧត្តមបណ្ឌិតបានគូសបញ្ជាក់ថា: "ការអភិវឌ្ឍន៍ធនធានមនុស្សឱ្យមានភាពរឹងមាំ ចាប់ផ្តើមពីមត្តេយ្យសាលានេះទៅ ដូចជាការធ្វើស្រែដើម្បីឱ្យបានទិន្នផលល្អ គឺចាប់ផ្តើមពីការធ្វើសំណាប"។

ចំណែកលោកឡុង សុផល អ្នកសម្របសម្រួលកម្មវិធីនៃគម្រោងអភិវឌ្ឍសហគមន៍ស្រុកអង្គស្នួល និងខណ្ឌពោធិ៍សែនជ័យនៅអង្គការជេអេសស៊ី មានប្រសាសន៍ថា: "គោលបំណងនៃការកសាងសាលាមត្តេយ្យ គឺដើម្បីជួយកុមារដែលមានអាយុពី៣ឆ្នាំ ដល់៦ឆ្នាំ ឱ្យហាត់ពត់លត់ដំ ដើម្បីឱ្យស្គាល់ថ្នាក់រៀន និងងាយស្រួលចូលបឋមសិក្សា"។



□hoto : □. ʃampho

លោកសោម ណែម អាយុ ៦៤ឆ្នាំ ដែលជាភ្ញៀវចូលរួម បាននិយាយថា លោកអបអរសាទរណាស់ដែលសមិទ្ធផលនេះបានផុសឡើង ពីព្រោះទាំងនេះនឹងជួយកុមារក្នុងភូមិបានរៀនសូត្រ។ ម្យ៉ាងទៀត អគារសាលានេះ នឹងសម្រាលបន្ទុកឪពុកម្តាយក្នុងការថែទាំកូនៗ ដើម្បីឱ្យមានពេលវេលាទៅប្រកបរបរផ្សេងទៀតដើម្បីលើកស្ទួយជីវភាពគ្រួសារ។

អគារដែលសម្ពោធនៅថ្ងៃនោះមាន២ខ្នងដែលមួយខ្នងមានបីបន្ទប់ គឺជាអំណោយរបស់រោងចក្រតៃយៀង និងខាំវែល។ ចំណែកអគារ១ខ្នងទៀតដែលមានឈ្មោះថា "អគារសមាគមបងស្រីអាត" បានសាងសង់ឡើង ដោយការចូលរួមរបស់សមាគមសាមគ្គីកសិករក្រីក្រ ចំនួន ១៧៦សមាគម ក្នុងចំនួនទឹកប្រាក់៥១.២៥៣.០០០រៀល និងសប្បុរសជនចូលរួម៤០.០០០រៀល សរុប ៥១.២៩៣.០០០ រៀលដែលស្មើ ១២.៣៧៦ដុល្លារ។ ដូច្នេះអង្គការជេអេសស៊ីចូលរួមឧបត្ថម្ភបង្គ្រប់ ២.៧៦៩ដុល្លារ។

សមាគមសាមគ្គីកសិករក្រីក្រ ត្រូវបានបង្កើតឡើងដោយគំនិតផ្តួចផ្តើមរបស់បងស្រីអាត ដែលជាអតីតអ្នកសម្របសម្រួលកម្មវិធីនៃគម្រោងអភិវឌ្ឍន៍សហគមន៍ ប្រចាំនៅស្រុកអង្គស្នួល ខេត្តកណ្តាល នៅអង្គការជេអេសស៊ី ។

បងស្រីបានទទួលមរណភាពហើយតាំងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ នៅប្រទេសបារាំង។ ដូច្នេះហើយទើបសាលាមត្តេយ្យ ដែលទើបនឹងសាងសង់ត្រូវបានប្រសិទ្ធនាមថា "សមាគមបងស្រីអាត"។

សមាគមកសិករក្រីក្របានបង្កើតឡើងតាំងពីឆ្នាំ១៩៩២ ដែលរើសយកកសិករក្រីក្រ ឱ្យចូលជាសមាជិកសមាគម ដោយសារគោលដៅនៃអង្គការជេអេសស៊ី គឺជួយដល់ជនពិការ និងអ្នកក្រីក្រ។

លោកឡុង សុផល មានប្រសាសន៍ឱ្យដឹងដែរថា សកម្មភាពរបស់សមាគម ធ្វើនៅស្រុកអង្គស្នួល នាខេត្តកណ្តាល ដែលគ្របដណ្តប់លើ ១២ឃុំ ត្រូវជា ២១៥ភូមិ។ ហើយសមាគមមានសកម្មភាពសំខាន់ពីរទី១ គឺឱ្យប្រជាកសិករខ្ចីប្រាក់ទៅធ្វើដើមទុនរកស៊ី។ ទី២សមាជិកក្នុងសមាគមអាចធ្វើការប្រវាស់គោ ឬធនាគារគោ។ ប៉ុន្តែនៅឆ្នាំដែលពួកគាត់ធ្វើការប្រវាស់គោ គឺគាត់មិនអាចខ្ចីលុយបានទេ។

អ្នកស្រីខុង ណារី អាយុ ៥១ឆ្នាំ សមាជិកម្នាក់របស់សមាគមមានប្រសាសន៍ថា : "ខ្ញុំសប្បាយចិត្ត ដោយបានចូលធ្វើជាសមាជិកសមាគម ពីព្រោះខ្ញុំអាចខ្ចីប្រាក់ ដែលវាមានអត្រាការប្រាក់ទាបជាងឈ្មួញ ឬក៏ធនាគារ ដើម្បីយកធ្វើមុខរបរបានងាយស្រួល។ អ្នកស្រីបន្តថា តាំងពីបានចូលជាសមាជិកសមាគមតាំងពីឆ្នាំ២០០០ មក ធ្វើឱ្យជីវភាពរបស់អ្នកស្រីប្រសើរជាងមុនច្រើនណាស់។



ប្រធានសមាគមប្រគល់ប្រាក់ឱ្យសមាជិកខ្ចីនៅភូមិក្រោក សង្កាត់បឹងធំ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ



□hoto : j. □hilong

**ខាន់ ភិរម្យ**

## កម្ពុជាត្រូវការអុស និងធ្យូង ១ ឆ្នាំប្រមាណ ៥,៥លានតោន

តំណាងអង្គការបរិស្ថានមួយរូប នៅក្នុងប្រទេសកម្ពុជាបានអះអាងថា នៅក្នុងមួយឆ្នាំ ប្រជាពលរដ្ឋកម្ពុជា ត្រូវការអុស និងធ្យូងប្រមាណជា ៥,៥លានតោន ។

លោកយូហាណេស អ៊ីវ៉ាន បាស្ទូ តំណាងអង្គការជេរ៉េស បានអះអាង កាលពីពេលថ្មីៗនេះ ថា អុស និងធ្យូង នៅតែជាប្រភពថាមពលចម្បងរបស់ ប្រជាពលរដ្ឋកម្ពុជា ហើយមកដល់ ពេលនេះ ថាមពលពីអុស និងធ្យូង នេះ គឺមានប្រជាជនកម្ពុជារាប់ហូតដល់ ទៅ ៨៤% នៅតែប្រើប្រាស់ ។ លោក បានឱ្យដឹងថា អុស និងធ្យូងសព្វថ្ងៃ នេះ គឺជាប្រភពថាមពលប្រមាណជា ៧០% នៃថាមពលសរុបដែលពលរដ្ឋ កម្ពុជាប្រើប្រាស់ ។ លោកបានឱ្យដឹង ថា នៅតំបន់ជនបទ ជាមធ្យម មួយ គ្រួសារត្រូវការ អុស និងធ្យូង ប្រមាណ ៥គីឡូក្រាម ក្នុងមួយថ្ងៃ ។ ដោយឡែក នៅទីក្រុងមានប្រើប្រាស់ ប្រមាណជា ២,១ គីឡូទេ ។ ក្នុង ចំណោមអុស និងធ្យូង ៥,៥លានតោន នោះប្រជាពលរដ្ឋក្រុងភ្នំពេញ ប្រើ ប្រាស់ប្រមាណ ៦៥០.០០០តោន ។

## ៥នាក់ស្លាប់ និង៥៤នាក់ របួស ដោយសារគ្រោះថ្នាក់ចរាចរណ៍

"គ្រោះថ្នាក់ចរាចរណ៍ ក្នុងមួយថ្ងៃ សម្លាប់ជីវិតប្រជាពលរដ្ឋកម្ពុជា ចំនួន ៥នាក់ និងធ្វើឱ្យរបួស យ៉ាងហោច ណាស់ក៏ ៥៤នាក់" ។ នេះបើតាម ព័ត៌មានដែល បានគេអះអាងកាលពី ចុងខែឧសភា ។

លោកពៅ ម៉ាលី អគ្គនាយករង ដឹកជញ្ជូន និងជាអគ្គលេខាធិការ គណៈកម្មាធិការជាតិសុវត្ថិភាព ចរាចរណ៍ផ្លូវ គោក បានអះអាងថា គិតមកដល់ឆ្នាំ ២០១០នេះ យានយន្ត ដែលចុះបញ្ជី មានចំនួនដល់ទៅ ១,៦ លានគ្រឿង ។ រីឯគ្រោះថ្នាក់ចរាចរណ៍ ក៏មានការ កើនឡើងផងដែរ ។

បើយោងទៅតាម របាយការណ៍ ប្រចាំឆ្នាំ២០១០ គ្រោះថ្នាក់ចរាចរណ៍ មានចំនួន ៦.៩៤១ ករណី ក្នុងនោះ មានជនរងគ្រោះ ១៨.២៨៧នាក់ ។ អ្នកស្លាប់មានចំនួន ១.៨១៦នាក់ របួសធ្ងន់មានចំនួន ៦.៧១៨ នាក់ និងរបួសស្រាលនោះ គឺមានចំនួន ៩.១៧០នាក់ផងដែរ ។

## តុលាការអន្តរជាតិដំណើរការ បណ្តឹងកម្ពុជាលើការបកស្រាយ សាលក្រមឆ្នាំ១៩៦២

សាវនាការលើបណ្តឹងរបស់កម្ពុជា ស្តីអំពីការបកស្រាយសាលក្រមនាឆ្នាំ ១៩៦២ ទៅកាន់តុលាការអន្តរជាតិ ទីក្រុងឡាអេ ប្រទេសហូឡង់ បាន ចាប់ផ្តើមកាលពីថ្ងៃទី៣០ ឧសភា ។

តាមទីភ្នាក់ងារព័ត៌មានបារាំង សាវនាការនេះបានចាប់ផ្តើមឡើង ដោយភាគីថៃ និងកម្ពុជា មានពេល ការពារទឡ្ហីករណ៍ម្នាង ១ម៉ោង ។ នៅ ថ្ងៃទីពីរ ភាគីទាំងពីរក៏មានពេលមួយ ម៉ោងម្នាង ដើម្បីឆ្លើយតបនឹង ទឡ្ហីករណ៍របស់ភាគីនីមួយៗ លើកឡើង ។

ថៃបានចោទប្រកាន់កម្ពុជាថា កម្ពុជាជាអ្នកវាយប្រហារទៅលើខ្លួន មុន ។ តែត្រូវកម្ពុជាបដិសេធដោយ សំអាងថា បើថៃស្រលាញ់សន្តិភាព ហើយជាប្រទេសរងគ្រោះ ហេតុអ្វី តែងតែបដិសេធយន្តការជម្លោះដោយ សន្តិវិធី? ក្រៅពីទឡ្ហីករណ៍នេះ មាន ទឡ្ហីករណ៍មួយចំនួនទៀត ត្រូវលើក ឡើង ។ ប៉ុន្តែគេនៅ មិនទាន់ដឹងថា តើ តុលាការសម្រេចយ៉ាងណានោះទេ?

## វៀតណាម និងចិន តឹងសរសៃករ ដាក់គ្នារឿងជម្លោះដែនទឹក

ក្រសួងការបរទេសវៀតណាម បានធ្វើការចោទប្រកាន់សាជាថ្មី ទៅកាន់ប្រទេសចិនថា ប្រទេសនេះរំលោភដែនអធិបតេយ្យភាព របស់ខ្លួននៅក្នុងដែនសមុទ្រចិនភាគខាងត្បូង។

បណ្តាញឃោសនារបស់វៀតណាម បានអះអាងថា ក្រុមហ៊ុន ប្រេង-ហ្គាសវៀតណាម ដែលគ្រប់គ្រងដោយរដ្ឋ បាននិយាយថា ប្រទេសចិនបានបំផ្លាញនូវកប៉ាល់រុករកប្រេងវៀតណាម។

ភាពតានតឹងបែបនេះបានកើតឡើងកាលពីចុងខែឧសភា ហើយ ប្រទេសទាំងពីរបានចោទប្រកាន់គ្នាទៅវិញទៅមកថា បានរំលោភ ទៅលើអធិបតេយ្យភាពនៅដែនសមុទ្រចិនខាងត្បូង ដែលជាតំបន់សម្បូរ ទៅដោយកំណប់រ៉ែប្រេងកាត។

អាជ្ញាធរវៀតណាម បានអះអាងថា យោធារបស់ចិនបានបង្ខំ ឱ្យប្រតិបត្តិការរុករករ៉ែប្រេងកាតរបស់វៀតណាម នៅក្នុងតំបន់ដែល មានជម្លោះនោះ មានភាពរាំងស្ទះ។

## អាល្លឺម៉ង់គ្រោងបិទរោងចក្រអគ្គិសនី ដើរដោយថាមពលនុយក្លេអ៊ែរ

លោកស្រីអេនជីឡា ម៉ាកកែល អធិការបតីអាល្លឺម៉ង់ បានថ្លែងប្រាប់ ពិភពលោកថា អាល្លឺម៉ង់មានផែនការនឹងបិទលែងឱ្យដំណើរការរោង-ចក្រផលិតថាមពលអគ្គិសនីដែលដើរដោយថាមពលនុយក្លេអ៊ែរឱ្យបាន មុនឆ្នាំ២០២២ ខាងមុខនេះ ។

លោកស្រីអេនជីឡា ម៉ាកកែល បានអះអាងថា អាល្លឺម៉ង់ចង់ធ្វើជា គំរូមួយ ហើយរោងចក្រថាមពលអគ្គិសនីដែលដើរដោយថាមពលនុយ-ក្លេអ៊ែរចំនួន ១៧កន្លែង ក្នុងប្រទេសនឹងត្រូវកំណត់កាលបរិច្ឆេទដើម្បី បិទឱ្យទៅតាមគោលដៅកំណត់ ។

បើតាមការអះអាងរបស់លោកស្រី ដែលត្រូវដកស្រង់សំដី ដោយ បណ្តាញពត៌មានបរទេសបានឱ្យដឹងថា ថាមពលដែលអាល្លឺម៉ង់នឹងយក មកជំនួសថាមពុលនុយក្លេអ៊ែរនោះ គឺជាថាមពលកកើតឡើងវិញ ។

លោកស្រីបានអះអាងថា អាល្លឺម៉ង់អាចក្លាយទៅជាប្រទេសឈាន មុខមួយសម្រាប់សករាជនៃប្រភពថាមពលករកើតឡើងវិញ ។

តាមផែនការអាល្លឺម៉ង់ គ្រោងនឹងបិទដំណើរការរោងចក្រថាមពល អគ្គិសនី ដែលដើរដោយ ថាមពលនុយក្លេអ៊ែ ចាស់របស់ខ្លួនចំនួន១៤ ត្រឹមឆ្នាំ២០២១ ។ហើយ រោងចក្រថ្មីបី ដែលទើប តែសាងសង់នឹងបន្ត រហូតដល់ឆ្នាំ ២០២២ ។



□hoto :dj□

**ខាន់ ភិរម្យ**

# ព្រាប កុល : “កូនកសិករមិនប្រាកដថា ត្រូវដើរកាន់កន្ទុយគោទេ”

## ខាន់ ភីរម្យ

*តើស្លឹកឈើពិតជាត្រូវជ្រុះមិនឆ្ងាយពីគល់ឬ? តើកូនកសិករនៅតែជាកសិករឬ? ដើម្បីដឹងចម្លើយនេះ អ្នកនាំសារសូមណែនាំឱ្យមិត្តអ្នកអានជួបជាមួយនិងលោកព្រាប កុល ដែលមានអតីតភាពជាកូនកសិករមួយរូបមកពីខេត្តស្វាយរៀង។ តែបច្ចុប្បន្ននេះ លោកជាឯកអគ្គរាជទូតសន្តិភាពមួយរូប។*




លោកព្រាប កុល ក្នុងវេទិកាយុវជនមួយ

**អ្នកនាំសារ : ជម្រាបសួរ ! តើលោកបានទទួលការតែងតាំងជាឯកអគ្គរាជទូតសន្តិភាពនៅពេលណាហើយស្ថាប័នណាដែលតែងតាំង ?**

**លោកព្រាប កុល** : ខ្ញុំបានក្លាយខ្លួនជាឯកអគ្គរាជទូតសន្តិភាពនេះ តាំងតែពីថ្ងៃទី២៥ ខែមិថុនា នៅឆ្នាំ២០១០ ដែលចេញដោយសហព័ន្ធសន្តិភាពសកលលោក ក្រោយពេលដែលខ្ញុំបានធ្វើការងារជាមួយយុវជនប្រមាណជាង ១០ឆ្នាំ កន្លងមក ។

**អ្នកនាំសារ: តើលោកបានធ្វើកិច្ចការអ្វីខ្លះជាមួយនឹងយុវជននាកន្លងមកនេះ ?**

**លោកព្រាប កុល** : ខ្ញុំបានធ្វើការជាប់ជាមួយនិងយុវជនលើបញ្ហាជាច្រើនរាប់តាំងពីការងារតស៊ូមតិ ពង្រឹងសមត្ថភាពជំនាញ ការងារសហគមន៍ អភិបាលកិច្ច ការងារឥណទាន និងការងារអាជីវកម្មខ្នាតតូច ហើយនិងការងារស្ម័គ្រចិត្តជាច្រើនទៀតដែលពាក់ព័ន្ធនឹងការងារយុវជននេះ ។

**អ្នកនាំសារ : តើលោកយល់ដូចម្តេចអំពីបញ្ហារបស់យុវជនកម្ពុជាប្រឈមពេលបច្ចុប្បន្ននេះ ?**

**លោកព្រាប កុល**: បច្ចុប្បន្ននេះ យុវជនកម្ពុជាកំពុងតែប្រឈមមុខនឹងបញ្ហាជាច្រើន ។ ប៉ុន្តែតាមការសង្កេតរបស់ខ្ញុំនៅពេលនេះបញ្ហាប្រឈមរបស់យុវជនច្រើនជាងគេនោះ គឺការងារធ្វើ ។ ក្នុងមួយឆ្នាំៗមានយុវជនប្រមាណពី ៣០០០០០នាក់ ត្រូវស្វែងរកការងារធ្វើ ។ នេះជាបញ្ហាបារម្ភដែលយុវជនម្នាក់ៗត្រូវតែគិត ហើយនិងត្រូវធ្វើយ៉ាងម៉េច ? ដើម្បីពង្រឹងសមត្ថភាពផ្ទាល់ខ្លួន និងដើម្បីប្រកួតប្រជែងក្នុងការស្វែងរកការងារធ្វើ ។

**អ្នកនាំសារ : តើយុវជនម្នាក់ៗ ត្រូវប្រឹងប្រែងយ៉ាងណាដើម្បីទទួលបានឱកាសការងារ និងទទួលជោគជ័យក្នុងជីវិត ?**

**លោកព្រាប កុល**: យុវជនត្រូវព្យាយាមដោយកុំផ្តេកផ្តួលនឹងវាសនា ។ ជីវិតគឺជាការប្រឹងប្រែង និងការតស៊ូ ។ តួយ៉ាងដូចជារូបខ្ញុំ ដែលមិនមែនជាមនុស្សដែលស្ថិតនៅក្នុងគ្រួសារនៅទីក្រុងឡើយ ។ ខ្ញុំកើតនៅក្នុងគ្រួសារកសិករមួយក្នុងស្រុកស្វាយជ្រុំខេត្តស្វាយរៀង ។ ប៉ុន្តែខ្ញុំបានប្រឹងប្រែងរៀននូវភាសា ហើយបានប្រើចំណេះដឹងភាសានេះរកលុយតាមរយៈការបង្រៀន តាំងពីអាយុ ១៣ឆ្នាំ ។ នៅអាយុ ១៧ឆ្នាំ ខ្ញុំបានក្លាយជាបុគ្គលិកជំនួយការនៅអង្គការក្រៅរដ្ឋាភិបាលមួយ ហើយបានអភិវឌ្ឍខ្លួនជាបន្តបន្ទាប់រហូតដល់ទទួលបានជោគជ័យនៅក្នុងការងារ និងទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកវិទ្យាសាស្ត្រនយោបាយ ។ កូនកសិករមិនប្រាកដថាត្រូវដើរដោយកាន់កន្ទុយគោរហូតនោះទេ ការតស៊ូគឺឱ្យយើងបានជោគជ័យ ។

**អ្នកនាំសារ : តើនាថ្ងៃអនាគតលោកមានសង្ឃឹមអ្វីទាក់ទងនឹងយុវជននេះ ?**

**លោកព្រាប កុល**: ក្តីសង្ឃឹមរបស់ខ្ញុំគឺចង់ឃើញយុវជនកម្ពុជាជោគជ័យដូចខ្ញុំ ។ ហើយសព្វថ្ងៃនេះខ្ញុំកំពុងអង្គុយសរសេរសៀវភៅមួយក្បាលដើម្បីចែករំលែកបទពិសោធន៍ជាមួយនឹងយុវជន ។




លោកព្រាប កុលដែលជាឯកអគ្គរាជទូតសន្តិភាពនៃសហព័ន្ធសន្តិភាពសកលលោក បានធ្វើការងារជាច្រើនជាពិសេសជាមួយយុវជនអស់ពេលជាច្រើនឆ្នាំ។ រូបលោកនៅក្នុងកម្មវិធី “គ្រឿងដំណែលកិត្តិយសនៃសន្តិភាព” ដែលជាសិក្ខាសាលាអប់រំមួយ។

### កូនកសិករក្លាយទៅជាឯកអគ្គរាជទូតសន្តិភាព

កូនកសិករមួយរូប ដែលមានបងប្អូនបង្កើតបីនាក់នៅក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង បច្ចុប្បន្ននេះ គឺជាឯកអគ្គរាជទូតសន្តិភាពសហព័ន្ធសន្តិភាពសកលលោក។

ក្នុងនាមជាកូនកសិករមួយរូបលោកព្រាប កុល បានអភិវឌ្ឍខ្លួនក្លាយជាគ្រូបង្រៀនភាសានៅអាយុ១៣ឆ្នាំ នាឆ្នាំ១៩៩៣ ហើយបានក្លាយខ្លួនជាបុគ្គលិកជំនួយការអង្គការក្រៅរដ្ឋាភិបាលមួយនៅក្នុងខេត្តនៅអាយុ១៧ឆ្នាំ។ លោកបានបន្តការសិក្សាផង និងធ្វើការផងរហូតដល់អភិវឌ្ឍខ្លួនក្លាយជាឯកអគ្គរាជទូតសន្តិភាពនៅក្នុងថ្ងៃទី២៥ មិថុនា ឆ្នាំ២០១០។ លោកចូលចិត្តឃ្លាមួយថា “កូនកសិករមិនចេះតែកាន់កន្ទុយគោទេ”។

# ព្រះសហគមន៍ : ការអប់រំគឺជាមូលដ្ឋានគ្រឹះរបស់ប្រទេស និ

**ខាន់ ភីរម្យ**



"រដ្ឋាភិបាលកម្ពុជា បានចាត់ទុកការអប់រំថា ជាស្នូលនៃការអភិវឌ្ឍន៍ និងផែនការកាត់បន្ថយភាពក្រីក្រ។ ចំណែកឯព្រះសហគមន៍ ក៏បានចាត់ទុកថាសំខាន់ ហើយក៏បានចូលរួមយ៉ាងសកម្ម។" នេះបើតាមការអះអាងរបស់តំណាងព្រះសហគមន៍កាតូលិកនៅក្នុងប្រទេស។

លោកសុខកុមារ អូលីវីយេ ជ្មីតអីស្លែរ អភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញ និងជាប្រធានគណៈកម្មាធិការអប់រំនៅក្នុងព្រះសហគមន៍កាតូលិក មានប្រសាសន៍ថា វិស័យអប់រំគឺសំខាន់ណាស់នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះហើយបានព្រះសហគមន៍ចាត់ទុកថា នេះជាការងារដ៏មានអាទិភាព ហើយបានចូលរួមយ៉ាងសកម្មជាមួយនិងរាជរដ្ឋាភិបាលកម្ពុជាដើម្បីអភិវឌ្ឍវិស័យនេះ ។

បើតាមប្រសាសន៍របស់លោកអភិបាល មកដល់ពេលនេះការងារអប់រំដែលព្រះសហគមន៍កំពុងតែចូលរួមចំណែកជាមួយនិងបណ្តាអង្គការសង្គមស៊ីវិលដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលនានានោះ គឺមានតាំងពីថ្នាក់មត្តេយ្យ ថ្នាក់ចំណេះដឹងទូទៅដែលមានចាប់ពីកម្រិតបឋមរហូតដល់កម្រិតវិទ្យាល័យ និងបន្តរហូតដល់ថ្នាក់ជំនាញបច្ចេកទេសនិងស្ថាប័នឧត្តមសិក្សា។

លោកអភិបាល អូលីវីយេ បញ្ជាក់ថា : "យើងមានកម្មវិធីអប់រំដែលណែនាំដោយក្រុមបព្វជិតា និងក្រុមបព្វជិតកាតូលិក។ យើងមានសាលាដុនបូស្កូសម្រាប់បណ្តុះបណ្តាលលើផ្នែកបច្ចេកទេស។ យើងមានអង្គការកាតូលិកមួយចំនួនទៀត ដូចជាមនុស្សលោកថ្មី គឺបានជួយការអប់រំនៅថ្នាក់សកលវិទ្យាល័យ និងការអប់រំដល់កុមារពិការជាដើម"។ លោកអភិបាលបន្តថា ព្រះសហគមន៍កាតូលិកបានចូលរួមអភិវឌ្ឍវិស័យអប់រំតាមរយៈសកម្មភាពពីរធំៗគឺកម្មវិធីអប់រំដែលត្រូវណែនាំ និងរៀបចំឡើងដោយក្រុមគ្រួសារសាសនទូត និងអង្គការកាតូលិកនានាដែលមាននៅក្នុងព្រះសហគមន៍ និងការងារអប់រំនៅតាមភូមិភាគ។

សម្រាប់ភូមិភាគភ្នំពេញ លោកអូលីវីយេ មានប្រសាសន៍ឱ្យដឹងថា សព្វថ្ងៃនេះ ព្រះសហគមន៍មានសាលាមត្តេយ្យ ទាំងនៅជនបទ និងទីក្រុង ចំនួន ២៥កន្លែង។ យើងមានវិទ្យាល័យសន្តប្រង់ស្វ័រនៅភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានសិស្សប្រមាណ ២៤០នាក់ កំពុងតែសិក្សានៅក្រោមអាហារូបករណ៍ ១០០%។ យើងក៏មានវិទ្យាស្ថានសន្តប៉ូលកសិកម្ម និងព័ត៌មានវិទ្យា នៅស្រុកត្រាំកក់ ខេត្តតាកែវដែលមាននិស្សិតប្រមាណ ២៧០នាក់ កំពុងតែសិក្សាឆ្នាំទី១ និងឆ្នាំទី២ ដោយនិស្សិតក្រីក្រខ្លះទទួលបានអាហារូបករណ៍ ១០០% ហើយនិស្សិតមួយចំនួនទទួលបានអាហារូបករណ៍ ៥០%។ លោកអូលីវីយេ បន្ថែមដែរថា ក្រៅពីនេះ យើងមានមណ្ឌលនិស្សិតជាច្រើនទៀតដែលកំពុងតែជួយផ្តល់ទីជម្រក និងអាហារូបករណ៍ដល់យុវជន និងយុវនារី មកពីខេត្តនានាប្រមាណ ៨០នាក់ផងដែរ។

ក្រៅពីភូមិភាគភ្នំពេញចេញ ភូមិភាគកំពង់ចាម និងភូមិភាគបាត់ដំបង ក៏បានកំពុងតែជំរុញសកម្មភាពអប់រំដល់កុមារ និងយុវជនក្នុងតំបន់ផងដែរ។

លោកសេរ៉ាលដឺវ៉ូសាំងបូជាចារ្យ ទទួលខុសត្រូវ

## ព្រះសហគមន៍កាតូលិកនៅកម្ពុជាបែងចែកជាបីភូមិភាគ

យោងទៅតាមសៀវភៅរចនាសម្ព័ន្ធព្រះសហគមន៍កាតូលិកនៅកម្ពុជា បានឱ្យដឹងថា ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជាបែងចែកជាបីភូមិភាគ គឺភ្នំពេញ កំពង់ចាម និងបាត់ដំបង។

ប្រភពដដែលនោះ បានឱ្យដឹងថា ភូមិភាគភ្នំពេញ គឺមានរដ្ឋធានីភ្នំពេញ កណ្តាល តាកែវ កំពត កោះកុង ព្រះសីហនុ កែប និងកំពង់ស្ពឺ។ ភូមិភាគកំពង់ចាម រួមមាន ខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តរតនគិរី។ ភូមិភាគបាត់ដំបង រួមមាន បាត់ដំបង ព្រះវិហារ សៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ និងប៉ៃលិន។

ប្រភពដដែលនោះបានឱ្យដឹងថា នៅក្នុងភូមិភាគនីមួយៗនោះ គឺគ្រប់គ្រងដោយអភិបាលមួយរូប។

# ះស និងយុទ្ធនាការកាត់បន្ថយភាពក្រីក្រ



□hoto : j. □hilong

ព្រះសហគមន៍កោះរកា នៃភូមិភាគកំពង់ចាមមាន ប្រសាសន៍ថា ដើម្បីរួមចំណែកលើកកម្ពស់វិស័យ អប់រំនេះព្រះសហគមន៍នៅភូមិភាគកំពង់ចាមមាន កម្មវិធីបួន គឺមណ្ឌលនិស្សិត មណ្ឌល អប់រំអក្ខរកម្ម អាហារូបករណ៍ និងកម្មវិធីអប់រំចំណេះទូទៅ។

លោកបូជាចារ្យ រៀបរាប់ថា សព្វថ្ងៃនេះនិស្សិត ប្រមាណ ១៥០នាក់ កំពុងតែស្នាក់នៅក្នុងមណ្ឌល និស្សិតក្នុងភូមិភាគយើង។ ក្រៅពីនេះ មាននិស្សិត ប្រមាណពី ៣០ ទៅ៤០នាក់ បានទទួលអាហារូប-ករណ៍មកសិក្សាលើថ្នាក់បរិញ្ញាបត្រនៅភ្នំពេញ។ យើងបង្កើតជាបណ្ណាល័យតាមភូមិដើម្បី អប់រំ និង ជំរុញការអាន និងគាំទ្រដល់កម្មវិធីអប់រំអក្ខរកម្ម។ យើងបានគាំទ្រទៅដល់ការបើកនូវវិទ្យាស្ថានមួយ ឈ្មោះចម្រើនវិជ្ជា ដែលមានបណ្តុះបណ្តាលកម្មវិធី អប់រំផ្សេងៗ។ លោកបញ្ជាក់ថា : "ក្រៅពីនេះ ក៏ មានយុវជន និងយុវនារីមួយចំនួនទៀត ទទួលការ ឧបត្ថម្ភ ដោយផ្ទាល់របស់បូជាចារ្យម្នាក់ៗ ក្នុងព្រះ សហគមន៍ផងដែរ"។

លោកសិលា ទម្លាប់ សុផល ជាបូជាចារ្យមួយរូប នៅក្នុងព្រះសហគមន៍ភូមិភាគបាត់ដំបង បានមាន ប្រសាសន៍ថា សព្វថ្ងៃនេះ ព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង កំពុងតែគាំទ្រដល់វិស័យអប់រំ តាមរយៈកម្មវិធីមួយចំនួនដូចជា មណ្ឌលទេពអ៊ីម សម្រាប់ជួយដល់យុវជន និងយុវនារីមួយចំនួនបន្ត ការសិក្សានៅថ្នាក់ឧត្តមសិក្សា។ យើងមាននូវកម្មវិធី អប់រំបន្ថែមដល់និស្សិតកម្រិតមធ្យមសិក្សាលើមុខ ជំនាញវិទ្យាសាស្ត្រ។ ហើយក្រៅពីនោះ បូជាចារ្យ មួយចំនួនទៀតក៏បានផ្តល់ការគាំទ្រដល់និស្សិត ក្រីក្រ ឱ្យទទួលបានការសិក្សានៅថ្នាក់ឧត្តម តាម រយៈកម្មវិធីឥណទាន សិក្សាជាដើម។ លោកបាន បញ្ជាក់ថា : "សម្រាប់ខ្លួនខ្ញុំកំពុងជួយយុវជនក្រីក្រ តាមកម្មវិធីឥណទានសិក្សានេះ បាន៩នាក់ដែរ"។

ជំរុញកម្មវិធីអប់រំនេះលោកភិន ប៊ុនរឿន អតីត និស្សិតផ្នែកព័ត៌មានវិទ្យា នៅវិទ្យាស្ថានស៊ីតិច នៅ ភ្នំពេញ សព្វថ្ងៃ ជាអ្នកឯកទេសខាងរចនាការកាត់ ត និងជាអ្នកបច្ចេកវិទ្យាព័ត៌មាន បានឱ្យដឹងដែរថា លោកអាចប្រើប្រាស់ និងចេះធ្វើការងារទាំងនេះគឺ ដោយសារតែកម្មវិធីអប់រំរបស់ព្រះសហគមន៍។ ប៊ុនរឿន គឺជាអតីតយុវជនមួយរូបដែលទទួលបាន កម្មវិធីឥណទានពីលោកទម្លាប់ សុផល លើថ្លៃបង់ ការសិក្សា និងការហូបចុករយៈពេល ៤ឆ្នាំ។

លោកបានបញ្ជាក់ថា : "បើលោកបូជាចារ្យមិន ឱ្យខ្ចីលុយ និងថ្លៃហូបចុកមួយខែ ៦០ដុល្លារទេ។ តើខ្ញុំបានលុយពីណាមកបង់សាលា បើមួយឆ្នាំត្រូវ ចំណាយអស់ ៤០០ ដុល្លារ ?"។

ក្រៅពីជំរុញកម្មវិធីអប់រំ ដែលមានស្រាប់ក្នុង ពេលបច្ចុប្បន្ននេះ គោលដៅថ្មីរបស់ព្រះសហគមន៍ គឺផ្តោតសំខាន់ទៅលើកម្មវិធីអប់រំ នៅតាមសាលា មត្តេយ្យបន្ថែមទៀត ។

លោកសិលា ទម្លាប់ សុផល មានប្រសាសន៍ថា ព្រះសហគមន៍ នៅពេលនេះកំពុងផ្តោតការអប់រំ លើថ្នាក់មត្តេយ្យ។ លោកបញ្ជាក់ថា : "បើចង់ឱ្យ ឫស្សីត្រង់ល្អនោះ យើងត្រូវពត់តាំងពីទំពាំងទៅ។ ដូច្នេះហើយបានជាយើងផ្តោតទៅលើការអប់រំ ថ្នាក់មត្តេយ្យ"។

លោកអូលីវីយេមានប្រសាសន៍ដែរថា ធនធាន មនុស្ស គឺជាមូលដ្ឋាននៃការអភិវឌ្ឍន៍តែវាមិនមែន ជាធនធាន ដែលងាយនឹងកសាងនោះទេ។ លោក បញ្ជាក់ថា : "ការសាងសង់ផ្ទះល្អមួយរួច អាចប្រើ ប្រាស់នូវពេលត្រឹមតែ ១ឆ្នាំ ទៅ២ឆ្នាំទេ។ ប៉ុន្តែបើ យើងចង់កសាងធនធានមនុស្ស យើងត្រូវប្រើពេល ពី២០ទៅ៣០ឆ្នាំ ទើបបាន"។ លោកក៏បន្តទៀតថា ជាគោលដៅព្រះសហគមន៍មានគោលបំណងជំរុញ ឱ្យមានសាលាមត្តេយ្យនៅគ្រប់ព្រះសហគមន៍។

លោកស្រីម៉ារី ឡ័រ ជូលី អាយ៉ាឡា អ្នកសម្រប សម្រួលសាលាមត្តេយ្យ នៅភូមិភាគភ្នំពេញ មាន ប្រសាសន៍ថា យើងកំពុងតែជំរុញលើកគុណភាព និង កម្មវិធីអប់រំនៅថ្នាក់សាលាមត្តេយ្យនៅព្រះសហ-គមន៍នានារបស់យើង។ លោកស្រីបានឱ្យដឹងទៀត ថា ហើយដើម្បីឱ្យមានគុណភាព យើងតែងផ្តោត ការយកចិត្តទុកដាក់អប់រំគរុកោសល្យដល់អ្នកគ្រូ របស់យើងតាមរយៈការបើកនូវសិក្ខាសាលាជាបន្ត បន្ទាប់ ដើម្បីឱ្យពួកគាត់ចេះនូវវិធីសាស្ត្រគ្រប់គ្រង ថ្នាក់រៀនចេះអំពីរបៀបដែលត្រឹមត្រូវនៅក្នុងការ អប់រំកុមារ និងយល់ដឹងអំពីក្បួនខ្នាតគរុកោសល្យ ឱ្យត្រឹមត្រូវផងដែរ។

## អង្គការមនុស្សលោកថ្មី និងកម្មវិធីអប់រំកុមារពិការ

អង្គការមនុស្សលោកថ្មី បានអះអាងថា ក្រៅពីការអប់រំកុមារធម្មតា ព្រះសហគមន៍ក៏បានយកចិត្តទុកដាក់លើកម្មវិធីសិក្សាដល់កុមារពិការ និងកុមារពិការសតិបញ្ញាផងដែរពោល គឺព្រះសហគមន៍បានចូលរួមនៅក្នុងការលើកកម្ពស់កុមារពិការ។

លោកជីង ចាន់ឌី ប្រធានកម្មវិធីមួយនៃអង្គការមនុស្សលោកថ្មី ដែលជាអង្គការមួយរបស់ព្រះសហគមន៍ បានឱ្យដឹងថា មកដល់សព្វថ្ងៃនេះ អង្គការបានបើកដំណើរការមជ្ឈមណ្ឌលបណ្តុះបណ្តាលកុមារពិការ និងពិការសតិបញ្ញាចំនួន ៥ មណ្ឌលនៅក្នុងខេត្តចំនួន២។ លោកបានឱ្យដឹងថា នៅក្នុងមជ្ឈមណ្ឌលទាំង៥ យើងមានកុមារចំនួន ៩៨នាក់។ ពួកគេសុទ្ធតែជាកូនដែលនៅក្នុងគ្រួសារក្រីក្រ។ ពួកគេទទួលបានការអប់រំបណ្តុះបណ្តាល អក្សរ បំណិនជីវិត អាហារូបត្ថម្ភ កីឡា និង កម្មវិធីកំសាន្តជាដើម។ លោកបន្ថែមថា មណ្ឌលបណ្តុះបណ្តាលកុមារពិការទាំងនោះ គឺមាន៤ កន្លែងនៅក្នុងខេត្តកំពង់ឆ្នាំង និងមួយកន្លែង នៅក្នុងខេត្តកណ្តាល។

# ការវាយតម្លៃការរស់នៅ និងការសហការគ្រួសារសិស្សនៅព្រះសហគមន៍កំពង់រទេះ

**អ៊ឹម សុខន**

ការប្រជុំការវាយតម្លៃការរស់នៅ និងការសហការគ្រួសារសិស្សប្រព្រឹត្តទៅកាលពីថ្ងៃទី១៧ នាខែឧសភា នៅព្រះសហគមន៍កាតូលិកកំពង់រទេះ ខេត្តកំពង់ធំ នៅភូមិភាគកាតូលិកបាត់ដំបង ។

ការវាយតម្លៃអំពីការរស់នៅរបស់សិស្សានុសិស្ស និងការចូលរួមសហការ ពីមាតាបិតាសិស្ស គឺជាកត្តា ដ៏សំខាន់ដែលនឹងជួយជំរុញ ឱ្យការសិក្សារបស់កូនឱ្យកាន់តែមានភាពល្អប្រសើរ ។ ហើយកិច្ចប្រជុំមាតាបិតាសិស្សនេះក៏ធ្វើឡើង ដើម្បីរំឭកការដឹងគុណមាតាបិតាផងដែរ ។

បងស្រីផន ធីប អ្នកសម្របសម្រួលនៅកម្មវិធីនេះ មានប្រសាសន៍ថា នេះជាការសំខាន់ដែលរាល់សកម្មភាពរបស់ព្រះសហគមន៍ គួរមានការចូលរួមសហការពីអាណាព្យាបាលសិស្ស ទោះបីជាមណ្ឌលទទួលខុសត្រូវលើការសិក្សា និងការស្នាក់នៅរបស់សិស្សក៏ដោយ ។ ហើយព្រះសហគមន៍នៅតែយល់ថា កូនសិស្សទាំងនេះ ត្រូវការការយកចិត្តទុកដាក់ និងក្ដីស្រលាញ់ពីក្រុមគ្រួសាររបស់ខ្លួន ។ ម្យ៉ាងវិញទៀតនេះ ក៏ជាការដាស់តឿនសិស្សានុសិស្ស កុំឱ្យភ្លើតភ្លើន ទៅតាមការអូសទាញរបស់សង្គម តាមរយៈការប្រើប្រាស់ទូរស័ព្ទដែលហួសកម្រិត និងការស្លៀកពាក់មិនសមរម្យជាដើមព្រោះអ្វីៗ អស់ទាំងនេះ គឺវាទាន់សម័យហើយ ប៉ុន្តែវាក៏អាចបណ្ដាលឱ្យសិស្សានុសិស្សភ្លេចការសិក្សាផងដែរ ។



□hoto : fr. □orntip

គួរបញ្ជាក់ផងដែរថា សិស្សដែលទទួលបានការឧបត្ថម្ភពីមណ្ឌលសិស្សកំពង់រទេះនេះ គឺមានចំនួន ៥០ហើយដែលនៅក្នុងនោះ ៥០% គឺជាក្មេងកំព្រាដែលគ្មានម្ដាយឪពុក និងមកពីគ្រួសារក្រក្រី ហើយសិស្សទាំងនេះ បានរៀនចាប់ពីថ្នាក់ទី១-ទី១២នៅមណ្ឌលតម្រូវ ឱ្យក្រុមគ្រួសារសិស្សចូលរួមចំនួន ៤ម៉ឺនរៀលក្នុងមួយឆ្នាំៗ ។ កិច្ចប្រជុំមាតាបិតាសិស្សនេះតែងតែប្រារព្ធធ្វើឡើងរាល់មួយឆ្នាំម្ដង ។

# យើងជាគ្រីស្តបរិស័ទ មានបេសកកម្មយ៉ាងពិតប្រាកដនៅក្នុងសង្គម

អង្គសិក្ខាសាលាស្ដីអំពី "យើងជាគ្រីស្តបរិស័ទមានបេសកកម្មយ៉ាងពិតប្រាកដក្នុងសង្គម" ប្រព្រឹត្តទៅនៅព្រះសហគមន៍កាតូលិកកំពត ពីថ្ងៃទី៦-៧ ឧសភា ។ យុវជនប្រមាណ ៨០ នាក់បានចូលរួម ។

លោកផុន សុផល អ្នកសម្របសម្រួលកម្មវិធីឱ្យដឹងថា តួនាទីចម្បងក្នុងការចូលរួមបម្រើសង្គមមិនគ្រាន់តែជាតួនាទីត្រឹមតែលោកបូជាចារ្យ បងប្រុស បងស្រី ឬក្រុមអ្នកស្ម័គ្រអ្វីឡើយ ។ ប៉ុន្តែយើងដែលជាយុវជនរស់នៅក្នុងសង្គមនេះ គឺចាំបាច់ត្រូវយល់ដឹងអំពីការរស់នៅប្រចាំថ្ងៃរបស់ខ្លួន ធ្វើជាគំរូយុវជនល្អ និងកូនល្អ ។ លោកផុន សុផលក៏បន្តទៀតថា សិក្ខាសាលានេះគឺលើកយកនូវ ៣ចំនុចសំខាន់ មកពិភាក្សាគឺទីមួយ គុណតម្លៃការចូលរួមរបស់គ្រីស្តបរិស័ទនៅក្នុងសង្គម ដែលនេះមានន័យថា យុវជនគ្រីស្តបរិស័ទគឺត្រូវតែចេះថ្លឹងថ្លែងនូវទង្វើរបស់ខ្លួនដែលជំរុញឱ្យបាននូវសន្តិភាព ការអត់ឱន និងការយោគយល់អធ្យាស្រ័យគ្នា ។ ទីពីរ យើងគឺជាអ្នកកសាងនូវព្រះរាជព្រះជាម្ចាស់ ដែលវាមានន័យ ថាគ្រប់សកម្មភាពទាំងប៉ុន្មាន គឺត្រូវតែផ្ដើមចេញពីក្ដីស្រលាញ់ គឺដូចដែលព្រះយេស៊ូទ្រង់ស្រលាញ់បុត្រធីតារបស់ព្រះអង្គ ។ ទីបី យើងជាគ្រីស្តបរិស័ទត្រូវមានបេសកកម្មជានិច្ច ដែលទាំងនេះនឹងជួយផ្សារភ្ជាប់រវាងព្រះសហគមន៍ និងសង្គម ។

យ៉ាងណាមិញ លោកបន្តថា មិនថា យើងបានក្លាយខ្លួនជាគ្រីស្តបរិស័ទយូរយ៉ាងណាក៏ដោយ និងយកចិត្តទុកដាក់ទៅព្រះវិហារព្រមទាំងធ្វើអធិដ្ឋានជាប់លាប់យ៉ាងណាក្ដី ក៏នេះមិនគ្រប់គ្រាន់សម្រាប់យើងដែរ ដោយយើងត្រូវតែមានសកម្មភាពជួយសង្គម និងធ្វើជាមនុស្សសុចរិតក្នុងសង្គម ។

**សុខន**

## ពិធីជ្រមុជទឹកដល់កុមារនៅព្រះសហគមន៍កោះរកា



□hoto : eng ɔ:hun

ព្រះសហគមន៍កោះរកាក្រៅមានអំណរសប្បាយយ៉ាងក្រៃលែងដោយបានទទួលកូនៗ ចំនួន៥នាក់ឱ្យទទួលអគ្គសញ្ញាជ្រមុជទឹកទៅជាគ្រីស្តបរិស័ទ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១១។ បើតាមប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរ កូនត្រូវទទួលសាសនាតាមក្រុមគ្រួសារឪពុកម្ដាយ។ បើតាមប្រសាសន៍របស់ឪពុកម្ដាយ បានឱ្យដឹងថា វាជាការត្រឹមត្រូវដែលកូនៗ របស់ពួកគាត់បានទទួលពិធីជ្រមុជទឹក។ អ្នកស្រីបាន សែហុន ជាម្ដាយរបស់កុមារវណ្ណាធិរាជ្យ បានប្រាប់ឱ្យដឹងថា : "គាត់បានរកឃើញព្រះមួយអង្គ គាត់លែងភ័យខ្លាច និងធ្វើឱ្យគាត់មានសេរីភាព។ គាត់ចង់ឱ្យកូនរបស់គាត់ក្លាយជាគ្រីស្តបរិស័ទ"។

ចំណែកអ្នកស្រីថេន ម្ដាយរបស់កុមារាធីម កន្និកាបានប្រាប់ថា : "គាត់ចង់ឱ្យកូនស្រីដូចគាត់ ធ្វើជាគ្រីស្តបរិស័ទព្រោះគាត់ទទួលនូវភាពកក់ក្ដៅច្រើនពីព្រះយេស៊ូ។

លោកបូជាចារ្យសេរ៉ាល បានមានប្រសាសន៍ថា : "ត្រូវហើយ! ចង់ឱ្យកូនស្គាល់មាគ៌ារបស់ព្រះជាម្ចាស់ ឪពុកម្ដាយត្រូវ ធ្វើជាគំរូដ៏ល្អឱ្យកូន និងណែនាំកូនៗ ឱ្យស្គាល់ពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ តាមរយៈសកម្មភាព ឬកាយវិការផ្សេងៗ ដែលឪពុកម្ដាយធ្វើចំពោះកូន ដែលនឹងធ្វើឱ្យកូនស្គាល់ និងស្រឡាញ់ព្រះជាម្ចាស់។

**ម៉េង ឈុន**

## ដំណើរបូជនីយចរដោយជិះកង់នៅកំពង់ចាម

**អ៊ឹម សុខន**

ដំណើរបូជនីយចរដោយជិះកង់ ដែលមានរយៈចម្ងាយប្រមាណ ៩០គីឡូម៉ែត្រ រៀបចំឡើងដោយព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម មានយុវជនយុវនារីចូលរួមសរុប ៥០នាក់។ កម្មវិធីនេះប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១២-១៦ខែឧសភា។ ចំនុចចាប់ផ្តើមចេញដំណើរ គឺពីព្រះវិហារកំពង់ចាមឆ្ពោះទៅព្រះសហគមន៍ថ្មពេជ្រ បន្តទៅព្រះសហគមន៍សួង និងព្រះសហគមន៍ចម្លាក់ រួចត្រឡប់មកព្រះវិហារកំពង់ចាមវិញ។

ជាមួយនិងដំណើរបូជនីយចរនេះ នឹងមានការរិះគិតពីប្រធានបទ "ចូរកុំខ្មាសអៀន និងផ្តល់សក្ខីភាពពីជំនឿ"។

បងស្រីសុជាតិ អ្នកសម្របសម្រួលនៃកម្មវិធីបូជនីយចរនេះ បានរៀបរាប់ថា យើងពិភាក្សា និងរិះគិតលើបីចំនុច គឺនៅថ្ងៃទីមួយរិះគិតអំពីជំនឿរបស់ខ្លួនជាគ្រីស្តបរិស័ទ។ ថ្ងៃទីពីរគឺរិះគិតអំពីការខ្មាសអៀនរបស់ខ្លួនក្នុងការប្រាប់ថា ខ្លួនជាគ្រីស្ត-បរិស័ទនៅក្នុងសង្គម និងថ្ងៃទីបី គឺផ្តល់សក្ខីភាពជាគ្រីស្តបរិស័ទក្នុងសង្គម។ បងស្រីបន្តថា តាមអ្វីដែលសង្កេតឃើញ ទោះបីជាយុវជន ភាគច្រើននៅទីនេះអាចរស់នៅដោយបើកចំហពីជំនឿរបស់ខ្លួនក៏ប៉ុន្តែយើងនៅតែជឿថា គ្រប់គ្នាចាំបាច់ត្រូវទទួលបាននូវការលើកទឹកចិត្ត និងការណែនាំដ៏ល្អដល់ការប្រព្រឹត្តប្រចាំថ្ងៃរបស់ពួកគេ។

បងស្រីសុជាតិ បន្ថែមថា វាជាឱកាសមួយក្នុងការចែករំលែកបទពិសោធន៍ដល់បងប្អូនដែលទើបទទួលអគ្គសញ្ញាជ្រមុជទឹកថ្មី ដើម្បីឱ្យគេយល់កាន់តែច្បាស់ពីផ្លូវជីវិតដែលខ្លួនកំពុងតែដើរ។ ក្នុងនោះបងស្រីបញ្ជាក់ថា ទោះបីយើងទទួលស្គាល់ថា ខ្លួនជាបុត្រធីតារបស់ព្រះជាម្ចាស់។ ប៉ុន្តែយើងត្រូវតែបំពេញកិច្ចឱ្យសមជាកូនព្រះដោយយកព្រះអង្គជាគំរូមិនថា កន្លងមកយុវជនធ្លាប់ត្រូវមិត្តរួមសាលាថា អ្នកកាន់សាសនាយេស៊ូ ឬសាសនាដទៃទេនោះ។

## ដំណើរកម្មសិក្សា ក្រុមកុមារកំព្រារបស់ព្រះសហគមន៍កំពង់ចាម

កុមារប្រមាណជាង ១០០នាក់ បានចុះធ្វើកម្ម-សិក្សាអំពីវប្បធម៌ទូទៅនៅឯតំបន់រមណីយដ្ឋានភ្នំហាន់ជ័យ ដែលស្ថិតនៅខេត្តកំពង់ចាមកាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១។

លោកផាន់បូរ៉ា ប្រធានក្រុមសន្តរ៉ាំងសង់ ដឺប៉ូល និងជាអ្នកសម្របសម្រួលកម្មវិធី ក៏បាននិយាយថា នេះជាដំណើរកម្មសិក្សាកំសាន្តរបស់មណ្ឌលសកម្មភាពកុមារកំព្រាបានធ្វើឡើងរៀងរាល់ឆ្នាំ។ បន្ទាប់មកនៅថ្ងៃទី២៩ ឧសភា មណ្ឌលសកម្មភាពកុមារកំព្រានឹងបន្តរៀបចំនូវទិវាពលកម្មកុមារអន្តរជាតិដែលនឹងធ្វើឡើងនៅព្រះវិហារកំពង់ចាម នៅភូមិទួលស្បូវ សង្កាត់វាលវង់នាខេត្តកំពង់ចាម។ លោកផាន់បូរ៉ា បន្តថា កម្មវិធីទិវាពលកម្មកុមារអន្តរជាតិនេះ ក៏មាននូវវគ្គបង្ហាញស្តីអំពីសីលធម៌រស់នៅក្នុងសង្គមដល់កុមារដែរ។ ហើយទិវានេះនឹងមានកុមារអាយុពី៦-១៦ឆ្នាំ ប្រមាណ ២០០នាក់ មកចូលរួមព្រមទាំងកុមារដែលមកពីក្រុមគ្រួសារទីទាល់ក្រផ្សេងទៀតចំនួន ១០០នាក់ ផងដែរ។

លោកផាន់ បូរ៉ា និយាយទៀតថា ការបង្ហាញ ពីសីលធម៌រស់នៅគឺការទាក់ទងនិងការសំពះជម្រាបសួរអរគុណ និងការសុំទោសជាដើម ដោយសារតែកន្លងមកមណ្ឌលសង្កេតឃើញ គឺពាក្យទាំងនេះមិនសូវបានប្រើប្រាស់នៅក្នុងគ្រួសារទេ។ តួយ៉ាងដូចជានៅពេលមនុស្សចាស់ឬឪពុកម្តាយធ្វើខុសចំពោះកូនរបស់ខ្លួន ពួកគាត់ក៏មិនដែលនិយាយពាក្យសុំទោសទេ។ ទាំងនេះគឺជាទម្លាប់ ឬការបង្រៀន មិនសមស្របមួយសម្រាប់ការរស់នៅ។ ក្រៅពីសកម្មភាពសិក្សាស្វែងយល់អំពីសីលធម៌ក្នុងការរស់នៅ។

មណ្ឌលសកម្មភាពកុមារកំព្រាកំពង់ចាម គឺចាប់ដំណើរការក្នុងឆ្នាំ២០០៤។ សព្វថ្ងៃមណ្ឌលនេះមានសកម្មភាពដូចជា ការបង្រៀនអក្ខរកម្ម ភាសាអង់-គ្លេសថ្នាក់ដំបូង គូរគំនូរ លេងព្យាណូ ហាត់ច្រៀង និងរៀនអំពីសីលធម៌ អនាម័យ និងការសួរសុខទុក្ខចាស់ជរានៅក្នុងមណ្ឌល និងនៅតាមភូមិជាដើម។

**សុខន**

## យើងទាំងអស់គ្នាជួយថែរក្សាសម្បត្តិរួម

ផ្លូវជាខ្សែបណ្តាញមួយ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមក។ ដោយមើលឃើញមូលហេតុទាំងនេះហើយ ទើបធ្វើឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗ ចាប់ផ្តើមយកចិត្តទុកដាក់ នឹងហេដ្ឋារចនាសម្ព័ន្ធប្រទេសរបស់ខ្លួនគ្រប់ទីកន្លែង។ យ៉ាងណាមិញនៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍន៍ទៅលើវិស័យគមនា-គមន៍ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់។



□hoto : eng ɔ:hun

តួយ៉ាងដូចជានៅភូមិកោះរការក្រៅ កាលពីមុនមក មិនដែលមានស្ពាន ឬផ្លូវស្រួលប៉ុន្មានទេ។ ប៉ុន្តែក្នុង អំឡុងពេលចុងក្រោយនេះ ភូមិនេះបានប្រែមុខមាត់ថ្មី ដោយសារមានស្ពានឆ្លងទន្លេ និងផ្លូវក្រាលក្រួសក្រហមយ៉ាងស្រស់ស្អាត។

ទោះជាយ៉ាងណា ការអភិវឌ្ឍន៍នេះត្រូវតែទាមទារ ឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋដែលរស់ក្នុងតំបន់ផងដែរ។ ដោយការស្រឡាញ់សម្បត្តិរួមលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស យ៉ាងច្រើនកុះករ នៅសាលាបឋមសិក្សា កោះរកាក្រៅ ក្រោមការផ្តល់យោបល់ពីលោកនាយកសាលាផងនោះ បានចូលរួមជួសជុលផ្លូវមួយខ្សែ ដែលត្រូវហូរច្រោះដោយទឹកភ្លៀង និងដើម្បីទប់ស្កាត់កុំឱ្យមានការខូចខាតកាន់តែធ្ងន់ធ្ងរជាងនេះតទៅទៀត កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១។

ក្នុងបរិយាកាសដ៏សែនរីករាយនេះ ទាំងអស់គ្នាបានខិតខំជញ្ជូនដីទៅបំពេញនៅតាមក្រឡុក និងក្រហូងផ្លូវ ហើយខ្លះទៀតក៏បានយកស្មៅទៅដាំនៅជម្រាលផ្លូវដើម្បីទប់កុំឱ្យទឹកភ្លៀងច្រោះ។

សូមបញ្ជាក់ថា ផ្លូវមួយខ្សែនេះជាអំណោយរបស់រដ្ឋាភិបាលកម្ពុជា នឹងមូលនិធិអន្តរឃុំកោះរកាក្រៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។

**ម៉េង ឈុន**

# កិច្ចប្រជុំលើកទី១របស់ក្រុមបុព្វជិត និងបុព្វជិតា ព្រមនិងក្រុមគ្រីស្តបរិស័ទស្ម័គ្រចិត្ត

**អ៊ឹម សុខន**

មនុស្សប្រមាណ១០០នាក់ ដែលបានធ្វើការក្នុងនាមព្រះសហគមន៍កាតូលិកបានមកជួបជុំគ្នាដើម្បីចែករំលែកនូវបទពិសោធន៍ការងាររបស់ខ្លួន ហើយ ការជួបជុំនេះធ្វើឡើង កាលពីថ្ងៃទី២១ ខែឧសភា កន្លងទៅ នៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច នៅរាជធានីភ្នំពេញ។

កិច្ចប្រជុំលើកទីមួយនេះ មានសមាជិកចូលរួមចំនួន ១១៨នាក់ ដែលអ្នកទាំងនោះភាគច្រើនគឺជាជនបរទេស មកពីក្រុមបងប្រុសបងស្រី ហើយនិងអ្នកស្ម័គ្រចិត្តធ្វើការនៅក្នុងព្រះសហគមន៍កាតូលិកប្រទេសកម្ពុជា។

លោកអភិបាលសុខ កុមារ អូលីយេ ស្មីតអីស្លែរ បានមានប្រសាសន៍ថា: "ចំពោះយើងម្នាក់ៗ ជាជនបរទេសដែលបានដាក់ចិត្តមកបម្រើព្រះសហគមន៍ប្រទេសកម្ពុជា យើងត្រូវតែមានចិត្តស្រលាញ់ និងយកអាសាបងប្អូនគ្រប់គ្នា មិនថាអ្នកនោះ ជាគ្រីស្តបរិស័ទ ឬមិនមែនក៏ដោយ"។

កិច្ចប្រជុំនេះ បានដំណើរការទៅដោយមានការតាំងបង្ហាញនូវសកម្មភាពរបស់ក្រុមនីមួយៗ ដែលមានវត្តមាន និងការពន្យល់អំពីសកម្មភាព ដំណើរនៃក្រុមខ្លួន។ ទន្ទឹមនឹងនេះ មានការបែងចែកក្រុមពិភាក្សាដែលក្រុមនីមួយៗ តម្រូវឱ្យមានសមាជិកមកពីក្រុមផ្សេងៗគ្នាផងដែរ។

បងស្រីអាញ៉ែស ង្វៀន នៃក្រុមគ្រួសារឧបការគុណ បានបង្ហាញចំណាប់អារម្មណ៍ថា: "ខ្ញុំយល់ថានេះជាការប្រជុំមួយដែលល្អសម្រាប់យើងទាំងអស់គ្នាដើម្បីចែករំលែកនូវបទពិសោធន៍ការងាររបស់ខ្លួន។ នេះក៏ជាកម្លាំងចិត្តដែលជំរុញឱ្យយើងម្នាក់ៗអាចធ្វើកិច្ចការ ក្នុងនាមជាបុត្រធីតា ព្រះជាម្ចាស់ទៅមុខទៀតទោះបីយើងមកពីក្រុមផ្សេងគ្នា"។

សម្រាប់កញ្ញាវង មែនយីងមកពីក្រុមអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការពីហុងកុង ក៏ថ្លែងស្រដៀងគ្នានេះថា: "អ្វីដែលលើសអំពីនេះទៅទៀតនោះ ការប្រជុំនេះបានពាំនាំនូវបណ្តាញការសហការជាច្រើនដែលនេះគឺជាគន្លឹះនៃការបង្កើនល្បឿនការងារ ឱ្យកាន់តែលឿន និងមានភាពងាយស្រួល ព្រមទាំងមាននូវដំណោះស្រាយឱ្យសមស្រប នៅពេលដែលការងារជួបនូវឧបសគ្គ"។ កញ្ញាបានលើកឡើងបន្ទៀតថា ព្រះសហគមន៍មានកម្មវិធីជាច្រើននៅក្នុងសង្គមដូចជាវិស័យអប់រំវិស័យ សុខាភិបាល និងគរថ្លង់-ល- ហើយសកម្មភាពទាំងនេះ តម្រូវឱ្យមាននូវការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។

នៅក្នុងកិច្ចប្រជុំនេះលោកអភិបាលដែលជាអ្នកណែនាំកម្មវិធីនេះបានរំលឹកនូវបួនចំនុចទាក់ទងនឹងសកម្មភាពការងារពេលកំពុងថ្វាយអភិបូជាដូច្នេះថា សូមឱ្យធ្វើការទៅតាមសមត្ថភាពរបស់ខ្លួន និងគោរពគ្នា។ ទី២ យើងជាអំណរសប្បាយ របស់បងប្អូន ហើយបងប្អូនក៏ជាអំណរសប្បាយរបស់យើង។ ទី៣ គឺការលះបង់ដោយក្តីស្រលាញ់ និងស្រលាញ់របស់បងប្អូនទាំងនោះឱ្យដូចជាស្រលាញ់ខ្លួនឯងនិងចំនុចទី៤ គឺពុំត្រូវឃ្លាតឆ្ងាញពីព្រះជាម្ចាស់ ត្បិតយើងទាំងអស់គ្នារស់ជាធ្លុងតែមួយនិងព្រះជាម្ចាស់គង់នៅជាមួយយើងគ្រប់ពេលវេលា។

ជាចុងក្រោយ លោកអភិបាលភូមិភាគភ្នំពេញរូបនេះបានបន្តថា លោកបានបន្តកិច្ចប្រជុំនេះយ៉ាងហោចណាស់ ឱ្យបាន៣ដង ក្នុងរយៈពេលមួយឆ្នាំដើម្បីរក្សាឱ្យទំនាក់ទំនងនេះកាន់តែមានភាពជិតដិតរវាងគ្នា និងគ្នា។



Photo : Jokhorn

# មិនត្រូវគិតរឿងដែលនឹងបម្រុងកើតនៅថ្ងៃស្អែកឡើយ !

**អ៊ុំម សុខន**

លោកបូជាចារ្យហ្វ្រង់ស្វ័រ សារីយ៉េ បានមកបម្រើការងារ នៅប្រទេសកម្ពុជា តាមរយៈក្រុមសាសនទូតមេព (MEP) កាលពីឆ្នាំ១៩៩៨គឺក្នុងខែវិច្ឆិកា ។ សព្វថ្ងៃលោកគឺជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ពោធិ៍ចិនតុង និងគងនយនៅភ្នំពេញ និងខេត្តកណ្តាល ។ លោកបានចូលរៀនបួសកាលអាយុ ២៨ឆ្នាំនៅទីក្រុងប៉ារីសប្រទេសបារាំង ។ លោកមានស្រុកកំណើតនៅទីក្រុងអារីយ៉ង់ ប្រទេសបារាំង ។



□hoto :□ Jambath

លោកបូជាចារ្យរូបនេះបានរៀបរាប់អំពីជីវិតនៃការត្រាស់ហៅថា បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យក្នុងឆ្នាំ១៩៨៦ លោកបានចាប់ផ្តើមធ្វើការងារស្ម័គ្រចិត្តជាអ្នកសម្របសម្រួលក្នុងក្រុមកុមារកំព្រាមួយនៅទីក្រុងប៉ារីស ។ រយៈពេលជាង ៤ឆ្នាំ លោកគឺជាអ្នកស្តាប់ និងលេងជាមួយក្មេងកំព្រា ។ ពេលនោះលោកកាន់តែចាប់អារម្មណ៍អំពីជីវិតធម្មតាក្នុងការរស់នៅប្រចាំថ្ងៃដែលមានព្រះគម្ពីរអប់រំ ហើយនិងគំរូរបស់ព្រះយេស៊ូគ្រីស្ត ។ លោកប្រាប់ថា: "ប្រការសំខាន់ដែលធ្វើឱ្យខ្ញុំកាន់តែចាប់អារម្មណ៍ គឺជីវិតជាលក្ខណៈសាមញ្ញ គឺថាអ្វីដែលមាននៅក្នុងព្រះគម្ពីរគឺមិនរៀបរាប់ ឬបង្ហាញអំពីប្រពៃណីនោះឡើយ ។ ប៉ុន្តែជាជីវិតពិត ដែលមានព្រះយេស៊ូជាផ្លូវ" ។

ពីឆ្នាំ១៩៩២-១៩៩៨ លោកហ្វ្រង់ស្វ័រ សារីយ៉េ បានជួបនឹងបញ្ហាជាច្រើន ហើយក៏ដូចជាការល្បងនានា ឱ្យដើរចេញពីទេវវិទ្យាល័យ ។ ប៉ុន្តែអ្វីដែលអាចធ្វើរូបលោកអាចបន្តដំណើររហូតដល់ក្លាយជាបូជាចារ្យនោះ គឺលោកបានរិះគិតអំពីអត្ថន័យក្នុងអត្ថបទគម្ពីរ មានន័យថា យើងត្រូវចាប់អារម្មណ៍ពីសកម្មភាពប្រចាំថ្ងៃរបស់យើងនៅក្នុងមួយថ្ងៃ គឺមិនត្រូវគិតពីរឿងដែលនឹងបម្រុងកើតនៅថ្ងៃខាងមុខឡើយ ។ នេះគឺជារបៀបមួយជួយឱ្យរូបលោកអាចខ្លួនជាឧបត្ថម្ភក នៅឆ្នាំ១៩៩៨ ហើយនៅក្នុងឆ្នាំដដែលនោះ លោកបានទទួលអគ្គសញ្ញាជាបូជាចារ្យ ហើយលោកក៏ត្រូវបានក្រុមចាត់ឱ្យមកបម្រើព្រះសហគមន៍ប្រទេសកម្ពុជា នៅខែវិច្ឆិកា ។

លោកហ្វ្រង់ស្វ័រ សារីយ៉េនិយាយថា ការរស់នៅរបស់បុគ្គលម្នាក់ មិនអាចនិយាយថា មិនដែលជួបទៅនឹងបញ្ហាអ្វីនោះឡើយ ។ ប៉ុន្តែអ្វីដែលសំខាន់ គឺការនិយាយរកហេតុផល ដែលជាដំណោះស្រាយដ៏ប្រសើរសម្រាប់យើងម្នាក់ៗ ។លោកបន្តថា ប្រសិនបើយើងមិននិយាយនោះ គឺវាលំបាកសម្រាប់យើងក្នុងការបំពេញការងារ ។ លោកបន្ថែមថា អ្វីដែលព្រះជាម្ចាស់បង្រៀនយើង គឺឱ្យចេះស្រលាញ់ អ្នកដទៃ និងចាត់ទុកជាបងប្អូន និងសាសន៍តែមួយ ។

## ព្រះសហគមន៍នៅកម្ពុជាប្រារព្ធពិធីនៃការត្រាស់ហៅ

ព្រះសហគមន៍នៅប្រទេសកម្ពុជាបានរួបរួមគ្នាប្រារព្ធទិវានៃការត្រាស់ហៅ ដោយយកសម្តេចប៉ាបយ៉ូហានប៉ូលទី២ ជាអ្នកមានសុភមង្គលពេញលក្ខណៈ ធ្វើជាឧបការីកាលពីថ្ងៃទី១៤-១៥ ខែឧសភា មុននេះ។

ដោយឡែកនៅព្រះវិហារសន្តយ៉ូសែបផ្សារតូច និងព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ក៏បានប្រារព្ធពិធីនេះដោយមានអធិដ្ឋានតេហ្សេក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ និងមានការចូលរួមពីក្រុមអេម៉ាណូ-អែល សាមូអែល យុវជនយុវនារី និងមានតំណាងតាមព្រះសហគមន៍ក្នុងភូមិភាគទាំងបីផងដែរ។

លោកអភិបាលភូមិភាគភ្នំពេញ សុខកុមារ អូលីវីយេ មានប្រសាសន៍ថា: "ព្រះសហគមន៍ប្រារព្ធពិធីនេះនៅក្នុងអាទិត្យ ទី៤ នៃរដូវបុណ្យចម្លង។ ព្រះសហគមន៍រៀបចំអធិដ្ឋានសម្រាប់ការត្រាស់ហៅ ជាពិសេសការត្រាសហៅ ធ្វើជាបូជាចារ្យ និងជាអ្នកបម្រើព្រះសហគមន៍អស់មួយជីវិត។ ពិធីនេះនឹងជួយផ្តល់កម្លាំងឱ្យយើងភ្ញាក់ស្មារតី មានអំណរសប្បាយថែមទៀត និងឱ្យយុវជនយុវនារីចាប់អារម្មណ៍បម្រើព្រះសហគមន៍យ៉ាងពិតប្រាកដ។ លោកបន្តថា: "ព្រះជាម្ចាស់បានត្រាស់ហៅយើងឱ្យធ្វើដំណើរជាមួយព្រះអង្គឱ្យណែនាំ និងបំភ្លឺអ្នកដទៃ។ ប៉ុន្តែយើងម្នាក់ៗពុំទាន់ទទួលស្គាល់ និងស្តាប់ឮព្រះសូរសៀងរបស់ព្រះអង្គនៅឡើយ។ ដូច្នេះយើងអាចឆ្លើយតបនឹងការត្រាស់ហៅ និងធ្វើជាអ្នកគង្វាលល្អបានដោយយកគំរូ និងនៅជាប់ជិតស្និទ្ធជាមួយគង្វាលពិតប្រាកដ គឺព្រះយេស៊ូគ្រីស្ត។

លោកបូជាចារ្យអ៊ុន សុន ផ្តល់សក្ខីភាពថា: "ការត្រាស់ហៅជាការចែកចាយជីវិតយើងជាមួយអ្នកដទៃ។ ហើយប្រភពនៃជីវិតរបស់យើងគឺព្រះជាម្ចាស់"។

លោកផុន វាសនា សមាជិកក្រុមអេម៉ាណូអែលមានចំណាប់អារម្មណ៍ថា វាគឺជាឱកាសដ៏ពិសេសមួយដែលផ្តល់ឱ្យខ្ញុំអាចរិះគិតពិចារណាអំពីសេរីភាព និងការប្រើប្រាស់សេរីភាពក្នុងឋានៈជាគ្រីស្តបរិស័ទម្នាក់។ យុវនារីជិន សុភាព និយាយដែរថា កម្មវិធីធ្វើឱ្យនាងទទួលចំណេះដឹងជាច្រើនទាក់ទងទៅនឹងផ្លូវវិញ្ញាណដែលលោកអភិបាលបានចែកចាយ ហើយដែលឱ្យនាងកាន់តែស្រលាញ់ និងមានចិត្តចង់ជួយព្រះសហគមន៍កាន់តែខ្លាំងឡើងៗ។

**ញឹប ញឿន**

# វិភាគព្រឹត្តិការណ៍

# តើមានអ្វីពិតប្រាកដនៅពីក្រោយវាំងននៃការវាយប្រហារលីប៊ី?

**ជាត សំភី**



តាំងពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ មក ការបះបោលរបស់ប្រជាជននៅប្រទេសលីប៊ីដើម្បីទាមទារឱ្យកាន់តែមានសេរីភាព ប្រជាធិបតេយ្យ ការគោរពនូវសិទ្ធមនុស្ស ការបែងចែកធនធានឱ្យមានសមធម៌ និងការបំបាត់នូវអំពើពុករលួយបានធ្វើឱ្យរញ្ជួយទ្វីបអាហ្វ្រិកខាងជើង។

ក្នុងបរិបទនេះបញ្ហាស្ថិតនៅត្រង់ថា តើហេតុអ្វីបានជាក្រុមបស្ចិមប្រទេសដែលនាំមុខដោយបារាំង អាមេរិក និងអង់គ្លេស ប្រញាប់ប្រញាល់ក្នុងការវាយប្រហាររបបលោកហ្គាដាហ្វីលឿនម្ល៉េះ?

នេះជាការពិតណាស់។ក្រុមបស្ចិមប្រទេសអាចប្រកាសមានបំណងជួយដល់អ្នកបដិវត្តដែលស្រេកឃ្លានសេរីភាព និងចង់រលាស់ខ្លួន ចេញពីរបបផ្តាច់ការបង្ហូរឈាម ដែលមិនញញើត នឹងបាញ់ប្រហារលើជនស្លោះត្រង់ដែលគ្មានអាវុធ។ វាជាការច្បាស់លាស់ដែរថា ការវាយប្រហារមួយចំនួន ដែលមានគោលដៅដ៏ច្បាស់លាស់ គឺអាចធ្វើឱ្យរបបផ្តាច់ការដែលមិនឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជនដួលរលំ។ហើយការបង្ក្រាបនូវរបបលោកហ្គាដាហ្វីនោះ ក៏មានការចូលរួមដោយសហគមន៍អន្តរជាតិក្រោមឆត្ររបស់អង្គការសហប្រជាជាតិ ដោយរួមទាំងមហាអំណាចចិន និងរុស្ស៊ីផងដែរ តាមរយៈដំណោះស្រាយ លេខ១៩៧៣ នៃក្រុមប្រឹក្សាសន្តិ-សុខប្រចាំអង្គការសហប្រជាជាតិ។ នេះជាដំណោះស្រាយមួយរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ដែលត្រូវប្រកាន់យកនៅថ្ងៃទី១៧ ខែមីនាឆ្នាំ២០១១។ ដំណោះស្រាយនេះភ្ជាប់ទាក់ទងនឹងប្រទេសលីប៊ីនិងការបះបោលនៅលីប៊ី ដែលកំពុងតែបន្ត ដោយអនុញ្ញាតឱ្យប្រទេសមួយចំនួនដែលចង់ចូលរួម ធ្វើឱ្យសម្រេចបាននូវតំបន់ហាមការហោះហើរលើប្រទេសលីប៊ី ដោយការចាត់គ្រប់វិធានការចាំបាច់ដើម្បីការពារប្រជាជន និងតំបន់ស៊ីវិលដែលរងការវាយប្រហារ។

តើហេតុអ្វីបានមានការទាញចេញនូវដំណោះស្រាយនេះបាន? ពីព្រោះថា តើអន្តរជាតិអាចមិនអើពើយ៉ាងដូចម្តេចប្រឈមមុខនឹងការអំពាវនាវស្វែងរកការសង្គ្រោះពីអ្នកបះបោលនៅលីប៊ីដែលសុំយ៉ាងច្បាស់លាស់នូវជំនួយរបស់សហគមន៍អន្តរជាតិ? ឬមួយគេអាចមិនយកចិត្តទុកដាក់នឹងជោគវាសនារបស់ប្រជាជនអារ៉ាប់ ដែលអាស្រ័យលើអ្វីដែលកើតមាន ឡើងនៅប្រទេសលីប៊ី?

ទោះជាយ៉ាងណា តើបញ្ហាស្ថិតនៅត្រឹមប៉ុណ្ណឹងឬ? ឬមួយអាចជាបញ្ហាផ្សេងពីនេះ?

ការធ្វើនូវអន្តរាគមន៍យោធាដែលដឹកនាំដោយបារាំង អាមេរិក អង់គ្លេស និងអូតង់ ប្រឆាំងនឹងប្រទេសលីប៊ី អាចមានការរួមបញ្ចូលនូវហេតុផលភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចដែលមានសារៈសំខាន់យ៉ាងសំបើម ពីព្រោះលីប៊ីគឺជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានសេដ្ឋកិច្ចប្រេងធំៗជាងគេបង្អស់នៅក្នុងពិភពលោក។ លីប៊ីក្តាប់ទំហំ ៣,៥% នៃប្រេងបម្រុងពិភពលោក ត្រូវជាទ្វេដងនៃប្រេងរបស់សហរដ្ឋអាមេរិក។ហើយជាមួយនិង ៤៦,៥កោដិបារ៉ែលនៃប្រេងបម្រុង លីប៊ីមានសេដ្ឋ-កិច្ច ប្រេងធំបំផុតនៅទ្វីបអាហ្វ្រិក ដែលមានបន្ទាប់ពីប្រទេសនីហ្សេរីយ៉ា និងអាល់ហ្សេរី។

បើតាមអ្នកភូមិសាស្ត្រនយោបាយមួយចំនួន ក៏បានប្រតិបត្តិការនៅលីប៊ី ជាផ្នែកនៃកម្មវិធីយោធាដែលនឹងពង្រីកទៅដល់តំបន់មជ្ឈិមបូព៌ា និងតំបន់អាស៊ីកណ្តាល ហើយតំបន់ទាំងនេះ គឺមានការគ្រប់គ្រងច្រើនជាង៦០% នៃប្រេង និងឧស្ម័នធម្មជាតិបម្រុងនៅលើពិភពលោក ព្រមទាំងការរួមបញ្ចូលទាំងបំពង់បង្ហូរប្រេង និងឧស្ម័នហើយដែលប្រទេសអារ៉ាប់ អាចមាននៅចន្លោះរហូតដល់ពី ៦៦%ទៅ ៧៦% នៃរបស់ទាំងនេះ។

ហេតុដូច្នេះ តើប្រេង គឺជាជ័យភណ្ឌនៃសង្គ្រាមដឹកនាំដោយបស្ចិមប្រទេស ឬអង្គការអូតង់ឬ?



## ស្ថានភាពភូមិសាស្ត្រប្រទេសលីប៊ី

ប្រទេសលីប៊ីមានឈ្មោះជាផ្លូវការថា មហាជីម៉ាហ៊ីរីយ៉ា អារ៉ាប់លីប៊ី ប្រជាមានិតសង្គមនិយម។ ប្រទេសនេះគឺជាប្រទេសមួយនៅអាហ្វ្រិកខាងជើង ដែលមានព្រំដែនភាគខាងជើងជាប់នឹងសមុទ្រមេឌីទែរ៉ាណេ។ ភាគខាងលិចជាប់នឹងប្រទេសអាល់ហ្សេរី និងទុយនេស៊ី។ ខាងត្បូងជាប់ និងប្រទេសនីហ្សេ និងប្រទេសឆាដ និងខាងកើតជាប់នឹងប្រទេស ស៊ូដង់ និងប្រទេសអេហ្ស៊ីប។

ប្រទេសនេះមានផ្ទៃក្រឡា ១,៧៥៩,៥៤០គម២ និងមានប្រជាជនប្រមាណ ៦,១៧៣,៥៧៩នាក់ (ស្ថិតិឆ្នាំ២០០៨)។ ផលិតផលជាតិសរុបជាតិសរុបរបស់ប្រជាជនម្នាក់ៗ គឺ ១២,០២០ដុល្លារ ដែលធ្វើឱ្យលីប៊ីស្ថិត នៅក្នុងចំណោម ៥០ប្រទេសរុងរឿងជាងគេនៅលើពិភពលោក។




Photo : ផ្សាយ

# ពាក្យ "ធម្មតា" ក្លាយជាប្រធានបទកម្មវិធីពិព័រណ៍សិល្បៈមួយ

**ខាន់ ភីរម្យ**

ពាក្យដ៏សាមញ្ញមួយ"ធម្មតា" បានត្រូវសិល្បៈករខ្មែរមួយរូបឈ្មោះវុធ លីណូលើកយកធ្វើជាប្រធានបទនៅក្នុង កម្មវិធីពិព័រណ៍របស់ខ្លួន ដែលបានចាប់ផ្ដើមកាលពីថ្ងៃទី១៧ ខែឧសភា ដល់ថ្ងៃទី១២ ខែមិថុនា នៅមណ្ឌលបាសាក់។ មណ្ឌលបាសាក់ដែលជាមណ្ឌលធនធានសិល្បៈមួយ បានឱ្យដឹងថា ពិព័រណ៍នេះជាស្នាដៃរបស់សិល្បករវ័យក្មេងមួយរូបឈ្មោះវុធ លីណូ ។

វុធ លីណូក៏បាននិយាយថា ពិព័រណ៍នេះដំណើរការឡើងដោយរូបថតពណ៌ធម្មជាតិចំនួន ៩ផ្ទាំង ដែលព្យួរពីពិដានជា រាងរង្វង់ ហើយភ្ជាប់មកជាមួយនូវសម្លេង។ លោកបានឱ្យដឹងថា ពិព័រណ៍នេះមានបំណងរៀបចំឡើងដើម្បីចោទសួរពីព្រំដែនរវាងភាពជាឯកជន និងសាធារណៈភាពក្នុង និងភាពក្រៅរបស់មនុស្ស។ រូបថត ទាំង៩នោះ គឺជារូបថតរបស់មនុស្ស៩នាក់ ដែលត្រូវបានគេគូរមុខរហូតមើលលែងចំណាំបាន ហើយនៅតាមរូបថត មានជាឧបករណ៍សម្រាប់ស្ដាប់នូវសម្លេងដែលអ្នកទស្សនាអាចនឹងស្ដាប់រឿងរ៉ាវពិតដែលបុគ្គលនៅក្នុងរូបថតនោះ និយាយអំពីជីវិតរបស់ពួកគេ ។

លោកលីណូ បានបញ្ជាក់ថា : "ពិព័រណ៍បំផុសយើងឱ្យរិះគិតឡើងវិញនូវទស្សនៈ និងបញ្ហាដែលពុំសមហេតុផលទៅលើក្រុមបុរសស្រលាញ់បុរស និងការផ្ដល់អំណាចដល់ពួកគេតាមរយៈការឆ្លុះបញ្ចាំងនូវអត្តសញ្ញាណរបស់ខ្លួន" ។

លោកបានបន្តទៀតថា រូបថត ទាំងនេះគឺមានលក្ខណៈសាមញ្ញ ដូចជា រូបថតនៅក្នុងលិខិតឆ្លងដែនដែរ។ ប៉ុន្តែវាគឺជារូបថតដែលបង្ហាញផ្លូវដល់អ្នកទស្សនាទាំងឡាយឱ្យចូលទៅដល់រឿងរ៉ាវ និងជីវិត ដ៏សាំញ៉ាំមួយចំនួនរបស់អ្នកចូលរួមក្នុងកម្មវិធី ។

លោកវុធ លីណូ គឺជាសិល្បៈករខ្មែរវ័យក្មេងមួយរូប។ លោកកើតក្នុងឆ្នាំ១៩៨២។ មកដល់ពេលបច្ចុប្បន្ននេះ លោកត្រូវបានគេចាត់ទុកជាសិល្បៈករ ដ៏មានស្នាដៃ មួយរូប។ ហើយស្នាដៃដែលលោកធ្លាប់ទទួលបាន រួមមានស្នាដៃតាំងពិព័រណ៍នៅក្រោមប្រធានបទកម្លាំងឆក់ស្រួបដែលលោកបានចូលរួមនៅក្នុងកម្មវិធីតាំងពិព័រណ៍នៅក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង និងពិព័រណ៍រូបថតនៅមជ្ឈមណ្ឌលវប្បធម៌បារាំង។ លោកបានជាសិល្បករដែលបានបញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រសង្គម នៅទីក្រុងមែលបិន ប្រទេសអូស្ត្រាលី។

## អំណាន

### រឿងសង្សារប្រុស




ផ្កាយជាកីឡាករមកពីសៀមរាបដែលទើបនឹងផ្លាស់មករៀននៅភ្នំពេញ។គេជួបមេឃដែលជាសិស្សអ្នកលេងប្រចាំវិទ្យាល័យបាក់ទូក។ ជាច្រើនលើក ជាច្រើនសា មេឃធ្វើឱ្យផ្កាយមានមន្ទិលអំពីទំនាក់ទំនងពួកគេ : តើមេឃចាប់អារម្មណ៍លើគេ ឬគ្រាន់តែប្រើប្រាស់គេដើម្បីឈោង ទៅរកទំនាក់ទំនងជាមួយ ចន្ទថ្លា នារីដែលនៅបន្ទប់ជិតខាង? ម្ដងមេឃធ្វើល្អ ម្ដងកាច ម្ដងស្លូតបូត ម្ដងទ្រគោះបោះបោក ម្ដងផ្អែមល្ហែម... មានពេល ខ្លះគេក៏ប្រើក្រសែភ្នែកស្រទន់មកកាន់ផ្កាយទៀតផង។

ផ្កាយលែងយល់ហើយ។ នៅសាលារៀន មិត្តរួមថ្នាក់សើច ចំអកឱ្យគេថាជាខ្ទើយ ថាគេ ប្រុសស្រឡាញ់ប្រុស។ ផ្កាយព្យាយាមធ្វើឱ្យមេឃចាកចេញពីជីវិតគេ។ តែទន្ទឹមនឹងនេះដែរ គេនឹកមេឃរកស្មាន មិនត្រូវ...

រឿងសង្សារប្រុស ជាប្រលោមលោកបែបទំនើប ដែលសរសេររៀបរាប់ អំពីអារម្មណ៍មនុស្សស្រឡាញ់ភេទ ដូចគ្នា ពេលមានស្នេហា ពេលគេបោះបង់ ឬពេលខូចចិត្ត...។

រឿងនេះនិពន្ធដោយលោក ផ្កាយ Novels ។

### សំនួរចម្លើយអំពីអាស៊ាន




នាំអ្នកអានដែលចាប់អារម្មណ៍ និងចំណេះដឹងទូទៅ ឱ្យស្វែងយល់ និងសិក្សាស៊ីជម្រៅចំពោះសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថាអាស៊ាន (ASEAN) ។

នៅក្នុងចំណោមសំនួរចម្លើយទាំង ១០០ យើងក៏អាចដឹងពីរចនាសម្ព័ន្ធកាលប្រវត្តិនៃការចូលជាសមាជិករបស់ប្រទេសនីមួយៗ គោលបំណងនៃការបង្កើតសមាគម នេះ សន្និសញ្ញានានា ទំនាក់ទំនងលើវិស័យសេដ្ឋកិច្ច និងនយោបាយ កិច្ចប្រជុំសំខាន់ៗ គុណសម្បត្តិ និងគុណវិបត្តិនៃការចូលជាសមាជិក...។

សៀវភៅនេះក៏បង្ហាញផងដែរនូវទិន្នន័យសង្ខេបអំពីប្រទេស សមាជិកនីមួយៗ: ផ្ទៃដី រដ្ឋធានី ប្រជាជនភាសា រូបិយវត្ថុការរៀបចំរដ្ឋបាល សាសនា ឧស្សាហកម្ម (ការនាំចេញ-នាំចូល) ដៃគូពាណិជ្ជកម្ម អង្គនីតិបញ្ញត្តិ-ល-។

នៅចុងបញ្ចប់នៃសៀវភៅនេះ យើងឃើញមានមួយជំពូកបន្ថែម ដែលមានរាយនាមព្រះមហាក្សត្រខ្មែរតាំងពីសតវត្សរ៍ទីមួយ រហូតដល់បច្ចុប្បន្ននេះ និងតារាងរាយឈ្មោះប្រទេសនានាក្នុងពិភពលោក។

**ហួត សុជាតា**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## ខែមិថុនា ឆ្នាំ២០១១ ដោយលោកឪពុកឡាំងសង់ សេនីយ៍ឆាល់

**ថ្ងៃអាទិត្យទី៧ នៃបុណ្យចម្លង (ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១១) *(យ៉ូហាន ១៧,១-១១)***

ក្នុងអត្ថបទគម្ពីរដំណឹងល្អនេះ ព្រះយេស៊ូអង្វរព្រះជាម្ចាស់សម្រាប់សាវ័ករបស់ព្រះអង្គ មុនពេលព្រះអង្គបែកពីក្រុមសាវ័ក ហើយយាងត្រឡប់ទៅឯព្រះបិតាវិញ ។ នៅពេលព្រះយេស៊ូទូលអង្វរព្រះបិតានោះ ព្រះអង្គមានព្រះបន្ទូលថា " ទូលបង្គំបានសម្តែងព្រះនាមរបស់ព្រះអង្គ ឱ្យអស់អ្នកដែលព្រះអង្គញែកចេញពីលោកនេះ ប្រទានទូលបង្គំស្គាល់ហើយ" ។ ដូច្នេះព្រះយេស៊ូបញ្ជាក់ថា អស់អ្នកជឿគឺជាមនុស្សដែលញែកចេញពីលោកនេះ ។ ម្យ៉ាងទៀតអស់អ្នកជឿ គឺជាមនុស្សដែលលែងយកតម្រាប់តាមលោកីយ៍ ។ល ។ ព្រះយេស៊ូបញ្ជាក់ច្បាស់ថា គ្រីស្ត-បរិស័ទជាមនុស្សដែលត្រូវមានចិត្តក្លាហាន និងចាកចេញពីអំពើអាក្រក់ទាំងពួង ។

**បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១១) *(យ៉ូហាន ២០,១៩-២៣)***

នៅល្ងាចថ្ងៃអាទិត្យ ដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គផ្លុំលើពួកសាវ័ក ហើយផ្តល់បេសកកម្មមួយពិសេសទៅពួកគេ គឺបេសកកម្មស្រាយបាបក្នុងនាមព្រះជាម្ចាស់ផ្ទាល់ ។ តាមពិត រាល់ពេលព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឱ្យយាងចុះលើម្នាក់នោះ ព្រះអង្គប្រគល់បេសកកម្មមួយពិសេសឱ្យអ្នកនោះដែរ ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យកសាងព្រះសហគមន៍ដោយអំណោយទានទាំងប្រាំពីរ ដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ គឺមានប្រាជ្ញាញាណចេះពិចារណាដឹងខុសត្រូវគំនិតឈ្លាសវៃ មានចិត្តអង់អាចមានស្គាល់ព្រះជាម្ចាស់ចេះថ្វាយបង្គំ និងចេះគោរពកោតខ្លាចព្រះអង្គ សូមមើលអេសាយ (១១,១-២) ។

**បុណ្យលើកតម្កើងព្រះត្រៃឯក (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១១) *(យ៉ូហាន ៣,១៦-១៨)***

ពេលមានមនុស្សផ្សេងៗ ដែលរួមចិត្តគំនិតឯកភាពគ្នា ១០០% យើងធ្លាប់ថា ពួកគេមានចិត្តតែមួយថ្លើមតែមួយ ។ ម្យ៉ាងទៀត ក្នុងព្រះគម្ពី នៅពេលរៀបរាប់អំពីប្តី-ប្រពន្ធ ដែលស្រលាញ់គ្នាយ៉ាងខ្លាំងបំផុត មានសរសេរថា "គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយ" សូមមើល មក (១០,៨) ។

ឧទាហរណ៍ទាំងពីរនេះជួយយើង យល់ខ្លះៗអំពីព្រះតៃឯកដែលជាការអាថ៌កំបាំងមួយដ៏អស្ចារ្យ ។ ព្រះតៃឯក គឺព្រះបីអង្គផ្សេងពីគ្នា ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ) ដែលជាព្រះជាម្ចាស់តែមួយតាំងពីដើមដំបូងមក ។ ទោះបីព្រះអង្គទាំងបីមានឋានៈតែមួយ បំណងតែមួយ និងសេចក្តីស្រលាញ់តែមួយ ក៏ព្រះអង្គមានបុគ្គលិកលក្ខណៈខុសៗពីគ្នាដែរ ។ ដូច្នេះព្រះតៃឯកបង្ហាញឱ្យមនុស្សគ្រប់ជាតិសាសន៍យល់អំពីមាគ៌ាទៅជាធ្លុងតែមមួយ ។ ទោះជាមានលក្ខណៈប្រជាជនផ្សេងពីគ្នាក៏ដោយ ក៏គម្រោងការរបស់ព្រះជាម្ចាស់ គឺឱ្យមនុស្សដែលបែកខ្ញែកគ្នារួបរួមគ្នាជាធ្លុងតែមួយតែមួយមែន ។

**បុណ្យលើកតម្កើងព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រីស្ត (ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១) *(យ៉ូហាន ៦,៥១-៥៨)***

នៅរាត្រីមុនព្រះយេស៊ូសោយទុក្ខលំបាក ព្រះអង្គជប់លៀងសាវ័ក នោះទ្រង់យកនំប៉័ង និងស្រា ហើយមានព្រះបន្ទូលថា "នេះជារូបកាយរបស់ខ្ញុំ..." "នេះជាលោហិតរបស់ខ្ញុំ..." ។ ដោយសារគ្រីស្តបរិស័ទទទួលព្រះកាយ និងព្រះលោហិតឥតចេះឈប់ទេ ។ ព្រះសហគមន៍នៅតែជាព្រះកាយព្រះយេស៊ូ ដែលនៅរស់ហើយគ្រីស្តបរិស័ទជាសរីរាង្គពោរពេញ ដោយកម្លាំងរបស់ព្រះយេស៊ូ ។ ព្រះយេស៊ូផ្តត់ផ្គង់អាហារដល់ព្រះកាយព្រះអង្គ គឺព្រះសហគមន៍ដើម្បីបន្តបេសកកម្មរបស់ព្រះអង្គផ្ទាល់ក្នុងលោកនេះ ហើយនៅថ្ងៃណាមួយដើម្បីទទួលជីវិតពេញលក្ខណៈរបស់ព្រះអង្គដែរ ។

## យុវវ័យជួយស្ត្រីដូចជួយខ្លួនឯង និងសង្គមជាតិ (ត) *(បទពាក្យប្រាំពីរ)*



**និពន្ធដោយ :**
**លោកស្រី ខុង ណារី**
**ថ្ងៃទី១៨ ឧសភា ២០១១**
**រៀបរៀងដោយ :**
**លោក ឡុង សុផល**

២១-ហេតុនេះគួរដឹងប្រឹងពិចារណ៍ ប្អូនអ្នកសិក្សាពេញវ័យស្រាប់
កុំឱ្យធ្លាក់ខ្លួនពួនឈោងចាប់ អំពើខុសច្បាប់ប្រញាប់ជៀស ។

២២-ប្អូនជាពលរដ្ឋដ៏គំរូ ត្រាប់ពាលកុំប្លូរនាំវិនាស
អាស្រូវកើ្តឹងឯងថ្លៃងរង្មៀស មិនអាចដូចមាសធ្លាក់ក្នុងជ្រាំ ។

២៣-ផ្លូវដែលបវរល្អថ្លៃថ្លា ជាស្ពានប្រាថ្នាយ៉ាងរឹងមាំ
នោះគឺវិជ្ជាម្ចាស់ឧត្តម មិនបាច់ថែទាំក៏មិនបាត់ ។

២៤-ស្និទ្ធចិត្តស្និទ្ធកាយស្និទ្ធត្រឹមត្រូវ សិក្សាជាផ្លូវនៅស្ពានស្ងាត់
អ្វីដែលហួងសៅត្រូវកំចាត់ រារាំងទប់ស្កាត់បាត់សូន្យសោះ ។

២៥-ប្អូនចេះត្រងត្រាប់ស្តាប់គន្លង ម៉ែឪញាតិផងនឹកស្រណោះ
យុវជនគំរូល្អឥតខ្ចោះ ត្រាប់ពូជបណ្តុះបណ្តាលល្អ ។

២៦-ចំណែកសិក្សាការអប់រំ ប្អូនត្រូវរៀបចំក្រមសីលធម៌
គោរពវិន័យស្តីជំហរ ក្រេបយកបន្តគ្រប់វិជ្ជា ។

២៧-វិជ្ជាពិសេសចេះខ្ជាប់ខ្ជួន ដឹកនាំពាំខ្លួនស្ងួនពុះពារ
រក្សាកិត្តិយសឈ្មោះអ្នកជា គ្រប់កិច្ចការងារដូចប្រាថ្នា ។

២៨-មិនអាចរលត់ផុតបាត់បង់ វិជ្ជាស្រោចស្រង់រាល់បញ្ហា
ងងឹតងងុលខ្វល់យ៉ាងណា វិជ្ជាសិក្សាបំភ្លឺផ្លូវ ។

២៩-ភាពល្ងិតល្ងង់ខ្លៅដៅជិតដាម មិនអាចជាប់ស្ពាមតាមតម្រូវ
ចាប់ពីពេលនេះរហូតទៅ វិជ្ជានាំផ្លូវទៅរកត្រើយ ។

៣០-សុភមង្គលផ្តល់ក្តីសុខ មិនបន្សល់ទុកល្ងិតទៀតឡើយ
ភ្លឺព្រោះវិជ្ជាគ្រានេះហើយ គ្រប់រូបបានស្បើយត្រើយវាសនា។

# ព្រះសហគមន៍កាតូលិកនៅភូមិភាគភ្នំពេញនៅក្នុងអំឡុងខែឧសភា

ដោយ សុជារិទ្ធ សុវណ្ណា សម្បត្តិ និងលោកឪពុកវីរជ័យ















# ព័ត៌មាន

## អង្គការមនុស្សលោកថ្មីប្រកាសរបាយការណ៍ស្រាវជ្រាវអំពីកុមារពិការសតិបញ្ញា



Photo : A. Jovanna

របាយការណ៍ស្រាវជ្រាវមួយស្តីអំពីពិការសតិ-បញ្ញានៅតំបន់ជនបទក្នុងប្រទេសកម្ពុជា : ទស្សនវប្បធម៌ និងបញ្ហាប្រឈមរបស់គ្រួសារ ត្រូវបានប្រកាសដោយអង្គការមនុស្សលោកថ្មី កាលពីថ្ងៃទី ២៥ ខែឧសភា កន្លងទៅនេះ ។

លោក អ៊ែរវ៉េ រ៉ូកឺប្លង់ នាយកប្រតិបត្តិអង្គការមនុស្សលោកថ្មី បានមានប្រសាសន៍ថា កុមារពិការសតិបញ្ញានៅតែទទួលការរើសអើងពីសង្គមគ្រួសារ និងសង្គមជាតិនៅពេលបច្ចុប្បន្ននេះ ។ មានគ្រួសារខ្លះបានលាក់បាំងនូវពិការភាពរបស់ពួកគេនៅពេលអ្នកជិតខាងមកលេងហើយ គ្រួសារមួយចំនួនតែងតែទុកកុមារនៅតែផ្ទះ និងកង្វះការថែទាំ ។

ជុំវិញបញ្ហាពិការនេះ លោកសែម សុខា ជារដ្ឋ-លេខាធិការក្រសួងសង្គមកិច្ច ក៏បានមានប្រសាសន៍ថា រដ្ឋាភិបាលក៏កំពុងតែផ្តោតការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍន៍ តែក៏មិនភ្លេចគិតអំពីកុមារ និងជនពិការនៅក្នុងប្រទេសដែរ ។ លោកក៏បានបន្តថា ទោះបីជារដ្ឋាភិបាលខិតខំប្រឹងប្រែងបណ្តុះបណ្តាលធនធានមនុស្សធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យក៏ដោយ ក៏រដ្ឋាភិបាលពុំព្រងើយកន្តើយនឹងការយកចិត្តទុកដាក់ចំពោះពិការភាពដែរដូចជាមនុស្សពិការ ឬក្មេងពិការសតិខាងបញ្ញាជាដើម ។ លោកបន្តថា កុមារពិការសតិបញ្ញាមានការលំបាកជាជាងពិការដៃជើង ព្រោះថាកុមារទាំងអស់នោះត្រូវការ"បេះដូងមនុស្សធម៌" អ្នកមើលថែទាំពេញមួយថ្ងៃពេញមួយជីវិត ដែលនេះជាការលះបង់ដ៏ធំធេង ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតច្បាប់ស្តីអំពីកិច្ចការពារ និងលើកកម្ពស់ ជនពិការ និងអនុក្រឹត្យមួយចំនួនទៀត ដើម្បីផ្តល់សិទ្ធិ និងការគាំទ្រសកម្មភាពរបស់ពួកគេ ។

លោកអាយ៉ាឡា ម៉ូរេយ៉ា រ៉ុណេ ប្រធានក្រុមសិក្សាស្រាវជ្រាវនេះបានឱ្យដឹងថា យោងទៅតាមការសិក្សាដែលធ្វើឡើង ទៅលើមនុស្សចំនួន ៧២ គ្រួសារនៅក្នុងស្រុកបរិបូណ៍ ខេត្តកំពង់ឆ្នាំង ក៏បានរកឃើញថាមូលហេតុដែលនាំឱ្យកុមារកម្ពុជាពិការសតិបញ្ញានោះ គឺអាណាព្យាបាលរបស់ពួកគេយល់ថា គឺដោយសារតែមាតា និងកុមារមានបញ្ហា កង្វះខាតអាហារូបបត្ថម្ភ ។ លោកនិយាយថា ៣៧,៥% នៃអាណាព្យាបាល ដែលផ្តល់ការសម្ភាសន៍យល់ថា កង្វះអាហាររូបបត្ថម្ភនេះ គឺជាមូល ហេតុចម្បងគេ ក្រៅពីនោះ មានដូចជាគ្រោះថ្នាក់ប៉ះក្បាល កម្លាំងអភិធម្មជាតិ និងគ្រុនក្តៅខ្លាំង-ល- ។

**ខាន់ ភីរម្យ**

## ការងារប្រចាំខែ

- ថ្ងៃទី០២ មិថុនា : នៅព្រះសហគមន៍ជុំគិរី ខេត្តតាកែវ មានគ្រូពេទ្យមកពិនិត្យ និងព្យាបាលភ្នែកជូនប្រជាជនដោយឥតគិតប្រាក់។
- ថ្ងៃទី៤-៥ មិថុនា : លោកអូលីវីយេ អភិបាលភូមិភាគភ្នំពេញ ណែនាំសំណាក់ធម៌យុវជនត្រៀមចូលរួមទិវាយុវជនពិភពលោក។
- ថ្ងៃទី៦-១០ មិថុនា : សំណាក់ធម៌បូជាចារ្យទូទាំងប្រទេសនៅក្រុងព្រះសីហនុ។
- ថ្ងៃទី០៧ មិថុនា : ព្រះសហគមន៍ព្រៃប្រស់នៅតំបន់កំពត មានគ្រូពេទ្យមកពិនិត្យ និងព្យាបាលភ្នែកជូនប្រជាជនដោយឥតគិតប្រាក់។
- ថ្ងៃទី១២ មិថុនា : សំណាក់ធម៌អ្នកលាបថ្វាស់ ៣០នាក់ នៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី១៤-២១ មិថុនា : ភ្ញៀវមកពីសិង្ហបុរីពី៥ ទៅ៦នាក់ ចុះមកសួរសុខទុក្ខទណ្ឌិត និងអ្នកជំងឺនៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី១៧-១៩ មិថុនា : សិក្ខាសាលាសម្រាប់អ្នកបម្រើអាសនៈនៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី២១ មិថុនា : លោកអភិបាលអូលីវីយេ ប្រជុំជាមួយប្រធានធំ និងក្រុមបងប្រុស និងបងស្រីវៀតណាមទាំងអស់ក្នុងភូមិភាគភ្នំពេញ។
- ថ្ងៃទី២៦ មិថុនា : ពិធីគោរពព្រះកាយ និងព្រះលោហិត មានគ្រីស្តបរិស័ទ ៣០នាក់ ទទួលព្រះកាយលើកទី១ នៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី២៦ មិថុនា : ពិធីគោរពសន្តសិលា និងសន្តប៉ូល និងប្រជុំអ្នកតំណាងភូមិភាគភ្នំពេញ ៥០នាក់ ដែលដឹកនាំដោយលោកអភិបាលអូលីវីយេ ផ្ទឹតអ៊ីស្លែរ នៅព្រះវិហារសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។


Radio Veritas Asia

Crossing Borders, Sharing Christ

**វិទ្យុវ៉េរីតាស់អាស៊ី (RVA)**

**ភាសាខ្មែរផ្សាយរយៈពេល ៣០នាទី រាល់ថ្ងៃ**

**តាមរលកធាតុអាកាសខ្លី (sw) :**

-ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុង រលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

-ស្តាប់វិទ្យុវ៉េរីតាស់ អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃ និងសង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកនៅកម្ពុជា។



**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង វីរជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧